ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2012, 10:25
CMS/CFO: Uch Arun

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>ជំនុំជម្រះក្តីនៅជំណាក់កាលដំបូង</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី៧៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វ៉េង ហ៊ិត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក កែត រេយ៍ន័រ *(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោកស្រី ទី ស្រ៊ីនណា

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក អឿន តាន (TCW-488) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក អឿន តាន** (TCW-488)

សួរដោយលោក អាកទួរ វែកគែន ផ្ដើមពី៖ .................................................... ទំព័រ ២
សួរដោយលោក សុន អរុណ ផ្ដើមពី៖ .................................................... ទំព័រ ២៩
សួរដោយលោក ម៉ៃខល កាណាវាស ផ្ដើមពី៖ .................................................... ទំព័រ៣៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន អង្គជំនុំជម្រះឲ្យក្រឡាបញ្ជី សែ កុលវុឌ្ឍី រាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះហៅឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់ខ្លួន ក្នុងការចូលរួមដំណើរការនីតិវិធីសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ សម្រាប់រយៈពេលពេញមួយថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ក្រឡាបញ្ជីកត់សម្គាល់ផងដែរ ពីវត្តមានលោកមេធាវី ម៉ម រិទ្ធា ដែលជាមេធាវីប្រឹក្សាសម្រាប់សាក្សី អឿន តាន នៅក្នុងសវនាការថ្ងៃនេះ។ សម្រាប់សាក្សីបម្រុងមិនមានទេនៅក្នុងសវនាការថ្ងៃនេះ។ សូមអរគុណ។

[០៩:០៥:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដានស្តាប់នូវកិច្ចដំណើរការសវនាការដោយផ្ទាល់យូរបាន។ ហើយយោងតាមអនុសាសន៍វេជ្ជបណ្ឌិតទទួលបន្ទុកពិនិត្យថែទាំព្យាបាលជនជាប់ចោទ នៅមន្ទីរឃុំឃាំងអ.វ.ត.ក

បានផ្តល់អនុសាសន៍ថា ក្នុងកិច្ចដំណើរការសវនាការសម្រាប់រយៈពេលនេះ គិតទាំងថ្ងៃ១៤ មិថុនា ឆ្នាំ ២០១២ នេះផង ជនជាប់ចោទគួរតែត្រូវបានទទួលការអនុញ្ញាតឲ្យនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ដោយហេតុលោក អៀង សារី មានអាការៈវិលមុខហេវហត់ ពិសេសនៅពេលឡើងជណ្ដើរ និងពុំមានលទ្ធភាពអង្គុយយូរបាន។

[០៩:០៦:៣៤]

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះជនជាប់ចោទ អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានផង។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់លោក អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមបន្ទប់សវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់ថិរវេលានៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាកទូរ វ៉ែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ អស់លោក លោកស្រីចៅក្រមជាទីគោរព សហភាតាទាំងអស់ជាទីគោរព ហើយនិងសាធារណជនផងដែរ។

[០៩:០៧:៥៩]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក អាកទូរ វ៉ែកគែន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ បាទ ខ្ញុំឈ្មោះ អាកទូរ វ៉ែកគែន ខ្ញុំជាមេធាវីរបស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរមួយចំនួនចោទទៅកាន់លោក ទាក់ទងទៅនឹងចម្លើយរបស់លោក ហើយនិង

ការឆ្លើយតបរបស់លោកនៅទីនេះតែម្តង។ នៅពេលស្តាប់ចម្លើយរបស់លោក នៅថ្ងៃ០៩ តុលា ឆ្នាំ ២០០៨ ដោយអ្នកស៊ើបអង្កេតនៃតុលាការយើងនេះ គាត់បានសួរលោកថា៖ “តើមុនពេលដណ្តើមបានទីក្រុងភ្នំពេញ លោកបានរស់នៅៗឧដុង្គ?” ហើយលោកបានឆ្លើយថា គឺទំព័រទី១២ ជាសំណៅជាភាសាបារាំង ERN 00235339, ជាភាសាខ្មែរ 00231809 ហើយជាភាសាអង់គ្លេស 00235134។ ដោយខ្ញុំសូមដកស្រង់៖ “ទេ មិនដែលទេ។ បន្ទាប់ពីបែកភ្នំពេញ ខ្ញុំចេញដំណើរពីកំពង់ចាម មកភ្នំពេញតែម្តង។ មុនចូលភ្នំពេញ ខ្ញុំមិនបានរស់នៅជាមួយ ប៉ុល ពត ទេ”។ បាទ ខ្ញុំសូមបញ្ចប់ការដកស្រង់ត្រឹមនេះ។ តើលោកចាំចម្លើយរបស់លោកនេះទេ ដែលលោកបានឆ្លើយទៅអ្នកស៊ើបអង្កេតនៃតុលាការយើងនេះ?

[០៩:១០:០៣]

**ប្រធានអង្គជំនុំ៖**

អៀង ធារិទ្ធ ឆ្លើយ! លោកស្តាប់យល់ទេនូវសំណួរ? បើសិនលោកស្តាប់សំណួរមិនយល់ទេអាចស្នើសុំឲ្យមេធាវីតាំងសំណួរលោកសាជាថ្មីម្តងទៀត ទីមួយ។ ទីពីរ លោកមេធាវីសូមបង្ហាញនូវខ្លឹមសារដែលអានដកស្រង់នេះឲ្យបានច្បាស់លាស់ ពីព្រោះតាមជាភាសាខ្មែរគឺអានហ្នឹងដកស្រង់យកមិនអស់ទេ ធ្វើឲ្យមានការភ័ន្តច្រឡំនូវខ្លឹមសារ។ នៅក្នុងនោះ គឺមានពាក្យមួយ “មុនពេលចូលភ្នំពេញមួយរយៈ” មានពាក្យ “មួយរយៈ” ទៀត ការបកប្រែជាភាសាខ្មែរអម្បាញ់មិញនេះមិនមានទេ។ អ៊ីចឹងសូមបញ្ជាក់ឲ្យប្រាប់គាត់ឡើងវិញឲ្យច្បាស់ ដើម្បីឲ្យសាក្សីហ្នឹងអាចយល់អំពីសំណួរ បំណងនៃការសួររបស់គាត់ទៅៗគាត់ ដើម្បីគាត់ឆ្លើយតបទៅនឹងសំណួរឲ្យបានត្រឹមត្រូវ។

[០៩:១១:១៨]

**លោក អាកទួរ វែកគែន៖**

បាទ ខ្ញុំយល់មិនច្បាស់ទេ មិនដឹងថាខ្ញុំធ្វើខុសកន្លែងណាទេលោកប្រធាន។ ខ្ញុំសូមចោទសំណួរម្តងទៀត ប៉ុន្តែខ្ញុំមិនដឹងថាមានបញ្ហាត្រង់ណានោះទេ អម្បាញ់មិញនេះ។

**ប្រធានអង្គជំនុំ៖**

លោកមិនមានបញ្ហាអីទេ ប៉ុន្តែមានបញ្ហាខាងសាក្សីស្តាប់នូវសំណួរដែលលោកសួរហ្នឹងមិនបាន គាត់នៅស្ងៀមមិនឆ្លើយតបនឹងសំណួរលោកទេ។ គាត់ត្រូវការឲ្យលោកសួរឡើងវិញម្តងទៀត បញ្ហាសំណួររបស់លោកយើងកត់សម្គាល់ខ្លួនឯង នៅភាសាខ្មែរដែលលោកដកស្រង់ហ្នឹង បានរំលងពាក្យ។ ពាក្យនេះធ្វើឲ្យវាខ្លឹមសារនៃចម្លើយនេះវាខុសធម្មតា ព្រោះគេមានពាក្យថា “មុនពេលចូលភ្នំពេញមួយ

រយៈ” ប៉ុន្តែពាក្យ “មួយរយៈ” នេះភាសាខ្មែរដែលលោកសួរហ្នឹងមិនមានទេអម្បាញ់មិញនេះ។ បើលោកដកស្រង់ៗ ឲ្យបានត្រឹមត្រូវនូវខ្លឹមសារទាំងមូលដែលៗ មាននៅក្នុងសេចក្ដីដកស្រង់នេះយកមកសួរ។

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

[០៩:១២:៣៨]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាននៅថ្ងៃ០៩ តុលា ឆ្នាំ២០០៨ អ្នកស៊ើបអង្កេតតុលាការបានចោទសំណួរលោកដូចតទៅនេះ។ បាទ ខ្ញុំសូមដកស្រង់៖ “សំណួរ៖ មុនបែកភ្នំពេញ តើលោកធ្លាប់រស់នៅស្តុកក្រោល ឧដុង្គ ជាមួយ ប៉ុល ពត ដែរឬទេ? ចម្លើយ៖ មិនធ្លាប់ទេ ក្រោយបែកភ្នំពេញ ខ្ញុំចេញដំណើរពីកំពង់ចាមមកភ្នំពេញតែម្តង។ មុនពេលចូលភ្នំពេញមួយរយៈ ខ្ញុំមិនបានរស់នៅជាមួយ ប៉ុល ពត ទេ។ ខ្ញុំមិនដឹងពីការជម្លៀសប្រជាជនចេញពីភ្នំពេញទេ”។ បាទ សូមបញ្ចប់ត្រឹមនេះ។ លោកសាក្សី តើលោកចាំ ចម្លើយ ហើយនិងសំណួររបស់លោកតបទៅនឹងសំណួរនេះដែរទេ?

**លោក អៀង តាន៖**

**ឆ៖** បាទ ខ្ញុំចាំខ្លះ មិនចាំខ្លះបាទ។ ដូច្នេះ មុនចូលភ្នំពេញក៏ខ្ញុំនៅកំពង់ចាម ក្រោយមកគឺមួយរយៈ គឺថាខ្ញុំបានចូលភ្នំពេញ។ ហើយក្នុងការចូលប្រជុំនៅស្តុកក្រោល ខ្ញុំមិនដែលដឹងទេបាទ។

**ស៖** តើលោកនៅស្តុកក្រោលជាមួយ ប៉ុល ពត មុនពេលដណ្តើមបានទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ ការប្រជុំស្តុកក្រោល ខ្ញុំអត់ចាំ  អត់ដឹងទេ ព្រោះខ្ញុំនៅកំពង់ចាមនោះ មុនរំដោះភ្នំពេញ។ តែដល់ក្រោយមក ខ្ញុំចុះ អត់ដឹងគេប្រជុំកន្លែងណាទេបាទ។

**ស៖** ខ្ញុំយល់ថា លោក-- អំពីការដែលលោកមិនចាំពីកិច្ចប្រជុំ ក៏ប៉ុន្តែនេះ មិនមែនជាសំណួររបស់ខ្ញុំនោះទេ។ សំណួរខ្ញុំ គឺថាតើលោកបានទៅស្តុកក្រោលនៅឧដុង្គ នៅក្នុងខេត្តកំពង់ស្ពឺ មុនពេលបែកភ្នំពេញដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលទេបាទ។

**ស៖** នៅពេលដែលលោកដឹងថា ភ្នំពេញបែកហើយ ម្សិលមិញលោកបានជម្រាបជូនថា លោកស្ថិតនៅត្រពាំងទឹម នៅក្នុងខេត្តកំពង់ចាម។ សំណួរខ្ញុំដូចតទៅនេះ នៅពេលដែលលោកដឹងថា បែកភ្នំពេញ តើ ប៉ុល ពត នៅជិតលោកដែរឬទេ នៅត្រពាំងទឹមនោះ នៅក្នុងខេត្តកំពង់ចាម?

**ឆ៖** បាទ ពេលនោះ ក៏ ប៉ុល ពត ក៏នៅជាប់នឹងកំពង់ចាមហ្នឹង ហ្នឹងពីមុនៗមកដល់ភ្នំពេញ។

[០៩:១៦:៤៦]

**ស៖** បាទ ឥឡូវហ្នឹង ខ្ញុំស្តាប់ចម្លើយបកប្រែរបស់លោកអម្បាញ់មិញនេះ បើសិនជាខ្ញុំជឿជាក់លើការបកប្រែ ចម្លើយរបស់លោក មិនបានឆ្លើយតបមកនឹងសំណួររបស់ខ្ញុំទេ។ ឥឡូវនេះ ខ្ញុំសូមសួរម្តងទៀត។ សំណួរខ្ញុំ គឺចង់ដឹងថា តើគឺថានៅថ្ងៃដែរ-- ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ជាថ្ងៃបែកភ្នំពេញ ឬក៏រំដោះភ្នំពេញ អាស្រ័យថា យើងនៅខាងណា។ តើ ប៉ុល ពត នៅជាមួយលោកនៅក្នុងខេត្តកំពង់ចាមដែរ ឬក៏អត់ នៅថ្ងៃដែលដណ្តើមបានទីក្រុងភ្នំពេញនោះ? តើលោក ប៉ុល ពត នៅជាមួយលោកដែរ ឬក៏អត់?

**ឆ៖** បាទ ពេលនោះន៎ៃ ខ្ញុំសូមបញ្ជាក់ថា សួរមួយៗ ដើម្បីខ្ញុំឆ្លើយច្បាស់ៗ។ ដល់ពេលសួរវែងៗអ៊ីចឹងទៅ ខ្ញុំតាមមិនទាន់បាទ។ សួរឲ្យច្បាស់ ឲ្យខ្លីៗ ព្រោះខ្ញុំស្តាប់ភាសាខ្មែរមិនសូវច្បាស់ បាទ។

**ប្រធានអង្គជំនុំ៖**

សាក្សី គាត់ចង់សួរអ៊ីចេះ! សួរថា តើនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នោះ ដែលជាថ្ងៃកងទ័ពខ្មែរក្រហមចូលវាយរំដោះទីក្រុងភ្នំពេញនោះ តើ ប៉ុល ពត មានវត្តមាននៅឯខេត្តកំពង់ចាមជាមួយលោកដែរឬទេ?

[០៩:១៨:២៧]

**លោក អឿន តាន៖**

បាទ ពេលនោះ គាត់មានវត្តមាននៅកំពង់ចាម បាទ។

**លោក អាកទូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** ក្រោយពីរំដោះរយៈពេលប៉ុន្មានដែល ប៉ុល ពត បានចេញពីកំពង់ចាម?

**លោក អឿន តាន៖**

**ឆ៖** ពេលក្រោយរំដោះភ្នំពេញ ក៏ ប៉ុល ពត បានចេញទៅ ន៎ៃ ចេញពីកំពង់ចាមទៅភ្នំពេញ ប្រហែលជាខ្ញុំនៅ ប្រហែលជាកន្លះខែ។ កន្លះខែមក គាត់ចូលភ្នំពេញតែម្តងបាទ។

**ស៖** បាទ ខ្ញុំមិនយល់ចម្លើយរបស់លោកបានច្បាស់ទេ។ ឥឡូវ ខ្ញុំសូមចោទសំណួរនេះម្តងទៀត តើក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ប៉ុន្មានថ្ងៃ លោក ប៉ុល ពត បានចេញពីកំពង់ចាម នៅកន្លែងដែល

គាត់នៅជាមួយលោកនោះ ដើម្បីមកទីក្រុងភ្នំពេញ។ តើក្រោយថ្ងៃ១៧ មេសា នុំង ប៉ុន្មានថ្ងៃ?

**ឆ៖** បាទ ពេលនោះក៏ក្រោយរំដោះភ្នំពេញមក ក៏លោក ប៉ុល ពត បានធ្វើដំណើរទៅភ្នំពេញ ប្រហែលជារំដោះភ្នំពេញ ប្រហែលក្រោយកន្លះខែបានគាត់ចេញមកភ្នំពេញ។ គាត់ចេញមកភ្នំពេញគឺ តាមរយៈជាមួយ ប៉ង់។ ឯខ្ញុំនៅឯកំពង់ចាមនោះ។ ក្រោយមកគឺ ប៉ង់ បានហៅខ្ញុំចូលភ្នំពេញវិញបាទ។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី គប្បីខិតខំស្តាប់សំណួរឲ្យបាន ហើយឆ្លើយតបនឹងត្រឹមកម្រិតដែលសួរបានហើយ។ សំណួរអម្បាញ់មិញ សួរពាក់ព័ន្ធតែរឿង ប៉ុល ពត ទេ។ ចំណែកឯរឿងលោក សំណួរគេបានសួរលោករួចហើយ។ អ៊ីចឹងដើម្បីកុំឲ្យមានការភ័ន្តច្រឡំ ហើយនិងច្របូកច្របល់ ឬក៏កុំឲ្យចំណាយពេលឥតប្រយោជន៍ សូមលោកសាក្សីស្តាប់សំណួរឲ្យបានច្បាស់ ហើយឆ្លើយតបត្រឹមសំណួរដែលសួរលោកប៉ុណ្ណោះ បានហើយ។

[០៩:២១:៣៤]

**លោក អាកទូរ វែកគែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** បើសិនជាខ្ញុំយល់មិនច្រឡំទេ លោកសាក្សី ភ្នំពេញដណ្តើមបាននៅថ្ងៃទី១៧ មេសា ឆ្នាំ ១៩៧៥ ហើយ១៥ថ្ងៃក្រោយមក គឺនៅចុងខែមេសា និងដើមខែឧសភា ឆ្នាំ១៩៧៥ លោក ប៉ុល ពត បាន ចូលមកទីក្រុងភ្នំពេញ តើអ៊ីចឹងមែនទេ?

**លោក អឿន តាន៖**

**ឆ៖** បាទ មែន ៗពិតហើយបាទ។

**ស៖** បើសិនជាខ្ញុំយល់ការផ្តល់ចម្លើយរបស់លោកមិនខុសទេ លោកផ្ទាល់គឺ ១៥ថ្ងៃក្រោយមក លោកបានមកជួប ប៉ុល ពត នៅទីក្រុងភ្នំពេញ គឺបានន័យថា ប្រហែលជានៅពាក់កណ្តាលខែឧសភា ឆ្នាំ១៩៧៥ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មែនហើយបាទ។

[០៩:២៣:២០]

**ស៖** ទាក់ទងទៅនឹងអ្នកដែលអមដំណើរ ប៉ុល ពត នៅពេលដែលគាត់ចេញដំណើរនៅចុងខែ

មេសា ដើមខែឧសភា ឆ្នាំ១៩៧៥ សំដៅទៅទីក្រុងភ្នំពេញ តើអ្នកណាជាអ្នកអមដំណើរ ប៉ុល ពត ក្នុងការធ្វើដំណើររវាងកំពង់ចាម និងភ្នំពេញនេះ? តើលោកដឹងថាអ្នកណាជាអ្នកអមដំណើរ ប៉ុល ពត ដែរឬទេ?

**ផ៖** បាទ ពេលនោះក៏ខ្ញុំដឹងថា គឺមាន ប៉ង់ អ្នកជូនដំណើរបាទ។

**ស៖** តើលោកបានឃើញ ប៉ង់ ចេញដំណើរជាមួយ ប៉ុល ពត ដែរឬទេ ក្នុងការធ្វើដំណើរពីកំពង់ចាម មកទីក្រុងភ្នំពេញនេះ?

**ផ៖** បាទ គឺឃើញបាទ។

**ស៖** ដូច្នេះបានន័យថា លោកបានឃើញការចេញដំណើររបស់ ប៉ុល ពត និង ប៉ង់ ដំណើរមកទីក្រុងភ្នំពេញ នៅចុងខែមេសា ដើមខែឧសភា នៅឆ្នាំ១៩៧៥ តើអ៊ីចឹងមែនទេ?

**ផ៖** បាទ អ៊ីចឹងមែនហើយបាទ។

[០៩:២៤:៥៥]

**ស៖** ការធ្វើដំណើររបស់ ប៉ុល ពត និង ប៉ង់ នេះ តើពួកគាត់ធ្វើដំណើរតែពីររូប ពីរនាក់គ្នាគាត់នោះទេ ឬក៏មានអ្នកផ្សេងទៀតអមដំណើរដែរ?

**ផ៖** បាទ មានអ្នកផ្សេងទៀត ដោយខ្ញុំមិនស្គាល់ឈ្មោះបាទ។

**ស៖** អ៊ីចឹង លោកអត់មានស្គាល់អ្នកណាទេ អ្នកដែលអមដំណើរផ្សេងទៀតនោះ?

**ផ៖** បាទ ខ្ញុំអត់ស្គាល់ទេ ខ្ញុំស្គាល់តែ ប៉ង់ ម្នាក់ បាទ។

**ស៖** ដូច្នេះ តើអ៊ីចឹងបានន័យថា យើងអាចនិយាយបានថា លោក ខៀវ សំផន មិនជូនដំណើរ ប៉ុល ពត ទេ ក្នុងការធ្វើដំណើរមកទីក្រុងភ្នំពេញនេះ។ តើត្រឹមត្រូវដែរឬទេ?

**ផ៖** បាទ ត្រឹមត្រូវហើយបាទ។

**ស៖** រូបលោកផ្ទាល់ លោកសាក្សី លោកបានមកដល់ទីក្រុងភ្នំពេញនៅពាក់កណ្ដាលខែឧសភា ឆ្នាំ១៩៧៥ ហើយលោកបានឆ្លើយថា លោកនៅមន្ទីរក-១ តែម្ដង តើអ៊ីចឹងមែនទេ?

[០៩:២៦:៤១]

**ផ៖** បាទ អ៊ីចឹងមែនហើយបាទ។

**ស៖** នៅពេលដែលលោកទៅដល់នោះ កន្លែងៗនោះ គឺថាចាប់ដំណើរៗហើយ មានការរៀបចំហើយគ្រប់គ្រាន់ហើយ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែនហើយបាទ។

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមនិយាយអំពីប្រធានបទកិច្ចប្រជុំដែលទំនងជាកើតឡើងនៅមន្ទីរក-១។ នៅពេលដែលលោកសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតតុលាការយើងថ្ងៃទី០៩ តុលា ឆ្នាំ២០០៨ លោកបាននិយាយអំពីប្រភេទប្រជុំពីរដែលធ្វើឡើងនៅមន្ទីរ ក-១ នៅពេលដែលលោកស្ថិតនៅទីនោះ នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យតែម្តង។ លោកបាននិយាយអំពីការប្រជុំទ្រង់ទ្រាយធំ ដែលមានអ្នកចូលរួមប្រហែលជា២០នាក់ ដែលអ្នកខ្លះមកពីភូមិភាគ ពីតំបន់ ហើយដែលជាកិច្ចប្រជុំដែល ប៉ុល ពត សុំឱ្យលោករៀបចំ ហើយកិច្ចប្រជុំនោះប្រព្រឹត្តទៅមួយខែម្តង។ លោកក៏បាននិយាយផងដែរ អំពីកិច្ចប្រជុំទ្រង់ទ្រាយតូចដែលមានអ្នកចូលរួមតិចជាង១០នាក់ កិច្ចប្រជុំនេះលោកមិនមែនជាអ្នករៀបចំនោះទេ ហើយដែលកិច្ចនេះប្រជុំប្រព្រឹត្តទៅប្រហែលជាពីរបីខែម្តង ពីបីទៅបួនខែម្តង។ តើលោកចាំចម្លើយរបស់លោកនេះទេ?

[០៩:២៩:០០]

**ឆ៖** បាទ ខ្ញុំចាំដែរ តែពេលយូរពេក ខ្ញុំភ្លេចៗខ្លះ ចាំខ្លះបាទ។ វាយូរពេកបាទ។

**ស៖** ទាក់ទងនឹងការប្រជុំទីមួយដែលលោកបាននិយាយថា ប្រភេទប្រជុំទីមួយ គឺថាប្រជុំទ្រង់ទ្រាយធំ ដែលធ្វើមួយខែម្តង ដែលមានអ្នកចូលរួមប្រហែលជា២០នាក់ជាង ដែលមានអ្នកខ្លះមកពីភូមិភាគនិងតំបន់។ នៅពេលដែលលោក-- គេស្តាប់ នៅពេលដែលគេស្តាប់ចម្លើយលោកនៅខែតុលា ឆ្នាំ ២០០៨ លោកបានឆ្លើយថា កិច្ចប្រជុំទាំងអស់នេះមានរយៈពេល-- ខ្ញុំសូមដកស្រង់ គឺថាលេខ ERN ជាភាសាបារាំង គឺ 00235332, ERN ជាភាសាអង់គ្លេសគឺ 00235128 ហើយ ERN ជាភាសាខ្មែរគឺ 00231801។ លោកបាននិយាយថា "គឺថាកិច្ចប្រជុំធំនេះ មានរយៈពេលពីប្រាំទៅប្រាំមួយថ្ងៃ ហើយអាចវែងយូរ ឬក៏ឆាប់ជាងហ្នឹង"។ តើលោកអាចបញ្ជាក់ចម្លើយនេះរបស់លោកបានទេ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់បញ្ហានេះ គឺថាពេលការប្រជុំ តែតាមការដឹង និងការឃើញ គឺថា ប្រជុំរយៈខ្លះ គឺថាវាយូរៗ។ ដល់ពេលខ្លះ គេហៅថា តាមរដ្ឋបាល ការងារវាតិច ក៏ប្រជុំឆាប់ចប់ដែរបាទ បើថា ការងារច្រើន គឺចំណាយបីថ្ងៃទៅបួនថ្ងៃបាទ។ ដូចបានចម្លើយពីខាងដើមហើយ តាមការសម្ភាសនេះបាទ។

[០៩:៣១:១៧]

**ស៖** បាទ ត្រង់ចំណុចហ្នឹងគឺថានៅពីកាលពីមុន គឺម្សិលមិញហ្នឹងតែម្តង លោកបានឆ្លើយថា

ការប្រជុំទ្រង់ទ្រាយធំនេះ ប្រព្រឹត្តឡើងមិនមែនម្តងមួយខែទេ ប៉ុន្តែជួនកាលគឺថា ពីរខែម្តង-- អំ! ពីរដងក្នុងមួយខែ ហើយលោកក៏បានប្រាប់ផងដែរថា មានរយៈពេលប្រហែលជាពីមួយថ្ងៃទៅពីរថ្ងៃ។ ដូច្នេះសំណួរខ្ញុំសួរលើភាពខុសគ្នានេះ ព្រោះលោកឆ្លើយខុសគ្នាថា ហេតុអ្វីបានមានភាពខុសគ្នារវាងការផ្តល់ចម្លើយរបស់លោកទៅអ្នកស៊ើបអង្កេតនៃតុលាការ ហើយនិងចម្លើយរបស់លោកនៅក្នុងបន្ទប់ជំនុំជម្រះនេះ?

**ឆ៖** ខ្ញុំច្រើនភ្លេចបាទ ខ្ញុំមិនចាំអាហ្នឹងវាយូរដែរហើយ ដល់សួរពេលនេះខ្ញុំមិនចាំ។ ដូច្នេះគឺថាសូមលោកបញ្ជាក់ខ្លីៗដូចពីដើមមក ពីមុនដំបូងអ៊ីចឹង ព្រោះបញ្ហាមិនចាំបាទ ព្រោះរយៈកាលកន្លងវាយូរ។ ដូច្នេះ ខ្ញុំមិនចាំទេ ព្រោះម៉្យាងមិនចេះអក្សរផង ន៎ៃ ក្តាប់នយោបាយក៏មិនសូវបាន វង្វេងវង្វាន់ភ្លេចមុខភ្លេចក្រោយអ៊ីចឹងទៅ។

**ស៖** ប្រសិនបើយើងធ្វើការគណនាឱ្យបានលឿននោះ លោកសាក្សី! បើយោងទៅតាមចម្លើយរបស់លោក ដែលលោកបានឆ្លើយខុសគ្នានោះ គឺមានន័យថា ក្នុងរយៈពេល៤៥-- ៤៤ខែ នៃរបបកម្ពុជាប្រជាធិបតេយ្យ គឺមានកិច្ចប្រជុំចន្លោះពី៤៤ ទៅ ៨៨ ដែលជាកិច្ចប្រជុំធំៗនៅមន្ទីរក-១ ហើយយើងឃើញថា ៣០ឆ្នាំជាងហើយ ក្រោយពេលកើតអង្គហេតុនោះ គឺនៅឆ្នាំ២០០៨ ឬក៏នៅថ្ងៃនេះ នៅសវនាការនេះ គឺលោកមិនអាចមានលទ្ធភាពក្នុងការបញ្ជាក់ឱ្យបានច្បាស់ទេថា តើលោក ខៀវ សំផន គាត់ធ្លាប់បានចូលរួមនៅក្នុងកិច្ចប្រជុំ៤៤ ទៅ ៨៨ នោះ ហើយក្នុងកិច្ចប្រជុំនោះដែរ ក៏លោកមិនបានចូលរួមដែរ។ ដូច្នេះលោកខ្លួនឯងផ្ទាល់នេះ ក៏លោកមិនដឹងអំពីប្រធានបទនៃកិច្ចប្រជុំដែលកើតឡើងក្នុងរយៈពេលបីខែ-- បីឆ្នាំនោះដែរ សូមទោស។ តើលោកគិតយ៉ាងម៉េចដែរ ចំពោះអ្វីដែលខ្ញុំលើកឡើងនេះ?

[០៩:៣៤:៣៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

សាក្សីកុំអាលទាន់ឆ្លើយតប!

**លោក អាប់ឌុលឡាក់ ថារីក៖**

នេះគឺជាប្រយោគដែលវែង យ៉ាងវែងអន្លាយ ហើយមានលេខតួលេខអីយ៉ាងច្រើន ខ្ញុំមិនជំទាស់ទៅលើការចោទសួរទេ ប៉ុន្តែខ្ញុំគិតថា គួរតែមានការកែប្រែឱ្យមានលក្ខណៈងាយស្រួល សាមញ្ញជាងនេះទៀតលោកប្រធាន។

**លោក អាកឡូ វែកគែន៖**

លោកប្រធាន ខ្ញុំគិតថាសាក្សីគាត់យល់ពីសំណួរខ្ញុំហើយ ហើយសូមឲ្យគាត់ឆ្លើយសិនទៅ។

**សួរដោយលោក អាកឡូ វែកគែន៖**

**ស៖** ហើយលោកសាក្សី ខ្ញុំសូមសួរលោកថា លោកយល់សំណួរខ្ញុំឬអត់?

**ប្រធានអង្គជំនុំ៖**

លោកកែសម្រួលទេ ឥឡូវលោកកែសម្រួលលើនេះទេ? លោកកែសម្រួលនូវសំណួររបស់លោកទេ? សំណួររបស់លោកពិតជាវែងមែន ទីមួយ។ ទីពីរ សំណួររបស់លោករបៀបធ្វើជាសេចក្ដីសន្និដ្ឋាន ហើយឲ្យសាក្សីឆ្លើយតប។ សំណួររបៀបនេះ យើងមិនអនុញ្ញាតឲ្យសាក្សីឆ្លើយទេ។

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរ ដែលសួរដោយមេធាវីអម្បាញ់មិញទេ ប្រសិនបើមេធាវីមិនកែសម្រួលសំណួរនេះសាជាថ្មី។

[០៩:៣៦:០៤]

**សួរដោយលោក អាកឡូ វែកគែន៖**

**ស៖** លោកសាក្សី៣០ឆ្នាំក្រោយមក តើលោកនឹកឃើញច្បាស់ទេអំពីកិច្ចប្រជុំធំៗ ដែលបានប្រព្រឹត្តទៅមន្ទីរក-១ ហើយនិងលោកមាននឹកឃើញអ្នកដែលបានចូលរួមនោះទេ?

**លោក អឿន តាន៖**

**ឆ៖** បាទ ពេលនោះក៏ខ្ញុំដូចបានបញ្ជាក់ខាងដើមហើយ ថាប្រធានបទនេះ ខ្ញុំមិនយល់ទេ ប្រធានបទ ដែលថានៃកិច្ចការប្រជុំវែងៗ កិច្ចការប្រជុំនៃហៅថា ធំៗ តែងឃើញរបៀបការប្រជុំ តែគឺថាខ្លួនក៏ពុំយល់ច្បាស់អំពីបញ្ហាកិច្ចការប្រជុំនោះ មិនដឹងគេប្រជុំរឿងអីបាទ។ ខ្ញុំមិនយល់អំពីប្រធានបទទេ ព្រោះខ្ញុំដូចបានបញ្ជាក់កាលពីម្សិលមិញអីចឹង។ ការចេះដឹង វាតិចតួចស្តួចស្តើង មិនសូវយល់អំពីបញ្ហាប្រធានបទយ៉ាងម៉េចៗទេបាទ។ ដល់អីចឹងដូចលោកប្រធានបានបញ្ជាក់ហើយថា សួរសំណួរឲ្យខ្លី ហើយឲ្យចំ ហើយខ្ញុំក្ដាប់បានទៀត។ ដល់សួរវែងអីចឹងទៅ ខ្ញុំដូចបានបញ្ជាក់ខាងដើម ខ្ញុំចាស់ ខួរក្បាលអន់ ដល់អីចឹងខ្ញុំតាមមិនបាន អត់ទាន់ទេ។ ដូចលោកប្រធានបានបញ្ជាក់ហើយថា សួរឲ្យខ្លីៗ ងាយស្រួលខ្ញុំតាមទាន់បាទ។

[០៩:៣៧:៥១]

**ស៖** សំណួររបស់ខ្ញុំគឺមិនផ្ដោតទៅលើប្រធានបទនៃកិច្ចប្រជុំ កិច្ចប្រជុំធំៗទាំងនេះទេ។ គឺខ្ញុំចង់

សំដៅទៅលើអ្នកដែលបានចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់នេះ។ តើលោកអាចបញ្ជាក់បានទេថា លោក ខៀវ សំផន នោះគាត់បានចូលរួមនៅក្នុងកិច្ចប្រជុំធំៗទាំងអស់ ដែលប្រព្រឹត្តទៅនៅមន្ទីរក-១ នោះ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់បញ្ហានេះគឺថា កិច្ចការប្រជុំធំៗមានការចូលរួមក៏មានលោក ខៀវ សំផន, លោក អៀង សារី, លោក នួន ជា ហើយក្រៅពីនេះខ្ញុំមិនស្គាល់ឈ្មោះ ខ្ញុំមិនអាចជម្រាបជូនទេបាទ។ ខ្ញុំស្គាល់ប៉ុនណា ខ្ញុំជូនប៉ុណ្ណឹង បាទ។

**ស៖** ខ្ញុំយល់ពីបញ្ហានេះច្បាស់ណាស់លោកសាក្សី ហេតុហ្នឹងហើយបានជាខ្ញុំសួរសំណួរដើម្បីឱ្យលោកបំភ្លឺឱ្យបានច្បាស់។ យើងកំពុងតែនិយាយអំពីកិច្ចប្រជុំជាង៥០ ដែលបានកើតឡើងក្នុងរយៈពេលជាងបីឆ្នាំ។ ហើយចំពោះខ្ញុំផ្ទាល់នេះ ខ្ញុំសួរលោកថាតើសក្ខីកម្មរបស់លោកនៅថ្ងៃនេះ នៅក្នុងសវនាការនេះ អាចបញ្ជាក់បានទេថា លោក ខៀវ សំផន នោះគាត់បានចូលរួមនៅក្នុងកិច្ចប្រជុំជាង៥០នេះនៅក្នុងរយៈពេលជាងបីខែនោះ? បីឆ្នាំនោះ សូមទោស។ សូមឱ្យលោកឆ្លើយថា ចាំ ឬមិនចាំ?

[០៩:៣៩:៣៩]

**ឆ៖** បាទ ខ្ញុំមិនសូវចាំទេ ដូចបញ្ជាក់ខាងដើមថា ការប្រជុំធំៗមានទាំង-- ដូចបញ្ជាក់ខាងដើមថាមានលោក ខៀវ សំផន, អៀង សារី, នួន ជា ហើយក្រៅពីនេះមានឈ្មោះជាច្រើនទៀត។ ដូច្នេះខ្ញុំមិនចាំឈ្មោះបាទ។

**ស៖** គឺមានន័យថា ចូលរួមគ្រប់កិច្ចប្រជុំទាំងអស់នៅក្នុងរយៈពេលបីឆ្នាំកន្លះនេះ តើមែនទេ?

**ឆ៖** បាទ មែនហើយ បាទ។

**ស៖** តើលោកអាចផ្ដល់កាលបរិច្ឆេទច្បាស់លាស់ណាមួយទេ គឺក្នុងចំណោមកិច្ចប្រជុំជាង៥០ហ្នឹង ដែលលោក ខៀវ សំផន បានចូលរួមនោះ?

**ឆ៖** បាទ ខ្ញុំបដិសេធបាន បាទ។

**ស៖** លោកសាក្សី ខ្ញុំនឹងសួរសំណួរនេះ ឡើងវិញម្ដងទៀត។ តើនៅថ្ងៃនេះ លោកអាចប្រាប់ដូចលើកជាឧទាហរណ៍ពីថ្ងៃណាមួយច្បាស់លាស់ ដែលថាមានកិច្ចប្រជុំ ក្នុងចំណោមកិច្ចប្រជុំទាំង៥០ជាង ដែលយើងកំពុងតែនិយាយនេះ?

**ឆ៖** បាទ ខ្ញុំមិនអាចរៀបរាប់បានទេ ព្រោះខ្ញុំក្ដាប់មិនបាន។ ក្ដាប់មិនបាន ត្រង់ថា វាភ្លេច វាយូរថ្ងៃ យូរឆ្នាំ។ ដូចនេះ គឺថាខ្ញុំមិនអាចជម្រាបបានទេបាទ។ ខ្ញុំភ្លេចអស់ហើយ មិនដឹងថ្ងៃណា ខែណា ឆ្នាំណាទេបាទ គ្រាន់ថាដឹងកិច្ចការប្រជុំនោះបាទ។

[០៩:៤២:២៦]

**ស៖** លោកសាក្សី គឺមានន័យថា ៣០ឆ្នាំ ក្រោយកើតអង្គហេតុនោះ គឺថាយើងមិនអាចចងចាំអំពីវត្តមានរបស់មនុស្សម្នាក់ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំជាង៥០ ដែលថា យើងខ្លួនឯងផ្ទាល់ហ្នឹងមិនបានចូលរួមទេ។ តើលោកមានយោបល់យ៉ាងណាដែរ?

**ប្រធានអង្គជំនុំ៖**

មិនចាំបាច់ឆ្លើយតបទេ! សំណួរនេះ សួររួចហើយ។ អង្គជំនុំជម្រះមិនត្រូវការស្ដាប់ចម្លើយតបសាក្សីចំពោះសំណួរចុងក្រោយរបស់មេធាវីនេះទេ។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** មានចំណុចមួយទៀត ដែលខ្ញុំមិនយល់នៅក្នុងសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់លោកកាលពីខែតុលា ឆ្នាំ២០០៨ នោះ។ គឺនៅទំព័រទី៦ ជាភាសាបារាំង ដែលមានលេខ ERN 00235333 ជាភាសាអង់គ្លេស 00235130, ជាភាសាខ្មែរ 0023--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យលោកមេធាវីអានលេខ ERN ជាភាសាខ្មែរម្ដងទៀត។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លេខ ERN ជាភាសាខ្មែរ 00231803។ គេបានសួរលោកនៅឆ្នាំ២០០៨ ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំតូចៗ ដែលប្រព្រឹត្តទៅនៅមន្ទីរក-១។ លោកបានបញ្ជាក់ថា មានកិច្ចប្រជុំតូចៗ នៅមន្ទីរក-១ ប៉ុន្តែលោកដឹងពីខ្លឹមសារ។ ខ្ញុំសូមដកស្រង់៖ “ការប្រជុំពិសេសៗ កើតឡើងតែក្នុងករណីចាំបាច់ ដូចជាការដោះស្រាយស្បៀង និងការលើកទំនប់ជាដើម”។ សូមបញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំ គឺខ្ញុំចង់ដឹងថា ចំពោះកិច្ចប្រជុំធំៗនោះលោកមិនដឹងអំពីខ្លឹមសារទេ ក៏ប៉ុន្តែអាម៉េចក៏បានទៅជាអាកិច្ចប្រជុំតូចៗនោះ ដែលមិនសូវកើតឡើងញឹកញាប់នោះ ហើយលោកមិនមែនជាអ្នករៀបចំទៀតនោះ បែរជាលោកអាចបញ្ជាក់អំពីខ្លឹមសារនៃកិច្ចប្រជុំនេះទៅវិញបាន? តើលោកអាចពន្យល់យ៉ាងម៉េចបានចំពោះចំណុចនេះ?

**ឆ៖** បាទ ខ្ញុំសូមពិភាក្សាជាមួយមេធាវីសិនបាទ។

[០៩:៤៥:៤៤]

*(សាក្សីពិភាក្សាជាមួយមេធាវីប្រឹក្សា)*

[០៩:៤៦:៤១]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ កិច្ចការប្រជុំធំៗ ហេតុអីបានដឹង? ដូចការរៀបចំ ដូច្នេះ ធ្វើតាមរយៈ ហៅថា ជម្រាបរបស់លោក ប៉ង់ អាហ្នឹងការប្រជុំធំៗ ដែលមានគ្នា២០នាក់។ ក្រោយមក គឺថា ប្រជុំតូចៗ ១០នាក់ ហេតុអីបានជាលោកដឹង? ក៏លោក ខ្លួនខ្ញុំផ្ទាល់គឺដឹង ក៏ដឹងតាមរយៈលោក ប៉ង់ បានជម្រាបខ្ញុំថា រៀបចំកន្លែងត្រូវការប្រជុំតូចៗ។ តូចៗនេះគឺថា គ្នា១០នាក់ ប្រជុំជួនណាមួយថ្ងៃចប់។ អាហ្នឹង ហ្នឹងគឺអ៊ីចឹង។ សូមមានមតិប៉ុណ្ណឹងបាទ។

[០៩:៤៧:៥៧]

**ស៖** លោកសាក្សី ចម្លើយរបស់លោកអម្បាញ់មិញនេះ គឺមានន័យថាលោករៀបចំកន្លែង សម្រាប់កិច្ចប្រជុំតូចៗ តើមានន័យថាអ៊ីចឹងមែនទេលោកសាក្សី?

**ឆ៖** បាទ អ៊ីចឹងមែនហើយបាទ។

**ស៖** ក៏ប៉ុន្តែនៅពេលដែលគេសួរលោកកាលពីមុនអំពីបញ្ហានោះ លោកនិយាយផ្ទុយពីនេះ។ លោកបានឆ្លើយថា លោកមិនមែនជាអ្នករៀបចំទេ សម្រាប់កិច្ចប្រជុំតូចៗនោះ។

**ឆ៖** បាទ ក្នុងការប្រជុំតូចៗ ដូចបានបញ្ជាក់ខាងដើមថា ខ្ញុំចាំមិនច្បាស់ ដូច្នេះគឺថា ផ្នែកខ្លួនខ្ញុំផ្ទាល់ គឺថាផ្នែកការពារ ហៅថាការពារ។ ដូច្នេះ ក៏ការរៀបចំ-- ដូច្នេះក៏ការសម្ភាសពីខាងដើម ខ្ញុំសម្រេចថានិយាយតាមកន្លែងសម្ភាសនោះ ដល់អ៊ីចឹងភ្លេច។ ដូច្នេះ ខ្ញុំសូមឯកភាពតាមសម្ភាសរបស់ពីអ្នកសម្ភាសពីមុន។ ដូច្នេះការចម្លើយរបស់ខ្ញុំគឺថា មិនចងចាំទេ ក្នុងហៅថាការនិយាយ មិនដូចមើលក្នុងអក្សរ ថ្ងៃនេះ ថ្ងៃនោះអត់ទេបាទ។

[០៩:៤៩:៤១]

**ស៖** ខ្ញុំចង់ឲ្យច្បាស់អំពីអ្វីដែលលោកនិយាយ តើលោកនិយាយថា លោកបានរៀបចំកិច្ចប្រជុំតូចៗ ឬក៏លោកមិនបានរៀបចំទេ ចំពោះកិច្ចប្រជុំតូចៗនោះ?

**ឆ៖** អានេះ ពិចារណារបស់ខ្ញុំ គឺថាពេលប្រជុំតូចៗ ដូច្នេះខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ ធ្វើការពិនិត្យនិងការនឹកឃើញរបស់ខ្ញុំផ្ទាល់ តែងគិតថា ការប្រជុំតូចៗ ដូច្នេះខ្ញុំជម្រាបច្បាស់ថា ខ្ញុំមិនបានរៀបចំទេបាទ។ ព្រោះខ្ញុំបញ្ជាក់អំមិញ គឺថាដូច្នេះ ខ្ញុំថាដូចចំ។ ការគិតគូរទៅ ការពិនិត្យពិចារណាទៅ គឺថាវាខុស ដល់ខុសថាខ្ញុំពេលប្រជុំតូចៗ ខ្ញុំមិនបានរៀបចំទេបាទ។ ពេលប្រជុំធំៗ ដូចបានបញ្ជាក់ខាងដើមថា មានលោក ប៉ង់ អ្នកដែលបញ្ជាថារៀបចំៗកន្លែងប្រជុំធំៗបាទ។

**ស៖** នៅពេលដែលអ្នកស៊ើបអង្កេតតុលាការ សួរសំណួរលោកនៅថ្ងៃ០៨ ខែតុលា ឆ្នាំ២០០៨ លោកបាននិយាយអំពីកិច្ចប្រជុំប្រភេទទីបី ដែលបានប្រព្រឹត្តទៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រោមអធិបតីភាពរបស់លោក ប៉ុល ពត ប៉ុន្តែមិនមែននៅមន្ទីរក-១ ទេ គឺនៅស្តាតអូឡាំពិក។ តើលោកមានចងចាំទេ ថាលោកបាននិយាយថាមានកិច្ចប្រជុំនៅស្តាតអូឡាំពិកនោះ?

**ឆ៖** បាទ គឺបានច្បាស់ គឺថាលោកបានជម្រាបយើងទៅ ខ្ញុំដឹង។ ខ្ញុំឃើញច្បាស់ថា ពេលប្រជុំនៅស្តាតអូឡាំពិក ក៏ខ្លួនខ្ញុំផ្ទាល់ឃើញ ទៅប្រជុំនេះ គឺដូចបានរៀបរាប់ហើយថា ឃើញការស្លៀកពាក់គេហៅថា យោធា ទៅប្រជុំយោធា។ ហើយខ្ញុំមើលទៅ គឺដឹកប្រជុំដោយមានលោក ប៉ុល ពត ហើយនិង សុន សេន។ ក្នុងនេះ គឺការប្រជុំឃើញមាន ឃើញស្លៀកពាក់ ខ្ញុំហៅថាយោធា ស្លៀកពាក់យោធា អ៊ីចឹង។ ប្រហែលគ្នា១០០ ទៅ២០០នាក់ បាទ។

[០៩:៥២:៣០]

**ស៖** តើលោកបានចូលរួមក្នុងកិច្ចប្រជុំប្រភេទនេះប៉ុន្មានដងដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** បាទ ខ្ញុំអត់ដែលចូមទេបាទ ព្រោះខ្ញុំខាងការពារ គ្រាន់តែឃើញថា ខ្ញុំនៅកន្លែងការពារដូចនៅក្រោយអាហ្នឹង ប៉ុល ពត គាត់ចូលប្រជុំអ៊ីចឹងទៅ ក៏ខ្ញុំនៅខាងក្រោយ ខាងក្រោមស្តាតអូឡាំពិក។ ដូច្នេះ ខ្លួនខ្ញុំផ្ទាល់អត់បានចូលរួមទេ គឺគ្មានសិទ្ធិ ព្រោះសិទ្ធិយើងវាតូច។ ដូច្នេះមិនដែលចូលប្រជុំទេបាទ។

**ស៖** គឺមានន័យថានៅៗក្រោយឆាក ស្តាតអូឡាំពិកមែនទេ?

**ឆ៖** បាទ មែនហើយបាទ។

[០៩:៥៣:៤៧]

**អ្នកបកប្រែ៖**

លោកប្រធាន សូមឱ្យសាក្សីឆ្លើយម្តងទៀត អ្នកបកប្រែអត់ឮ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីតាំងសំណួរសាជាថ្មីម្តងទៀត ចុងក្រោយអម្បាញ់មិញនេះ ព្រោះសាក្សីមិនទាន់បានឆ្លើយទេ។ ឆ្លើយមិនមានការបើកឧបករណ៍ ក្បាលមីក្រូមិនទាន់ប្រតិបត្តិការ។

**លោក អាកឡូរ វ៉ែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** នៅពេលដែលលោកនិយាយអំពីឆាកនៅខាងក្រោយ គឺថានៅខាងក្រោយ ឆាកខាងក្រោយ ស្តាតអូរឡាំពិក តើមែនទេ?

**លោក អឿន តាន៖**

**ឆ៖** បាទ គឺមែនហើយបាទ។

[០៩:៥៤:៤៧]

**ស៖** តើលោកទៅក្រោយឆាកស្តាតអូរឡាំពិកហ្នឹងប៉ុន្មានដងដែរក្នុងពេលដែល ប៉ុល ពត គាត់ទៅចូលរួមកិច្ចប្រជុំនៅទីនោះៗ?

**ឆ៖** បាន ខ្ញុំចូលក្នុងនេះ ពីរដងបាទ។

**ស៖** គឺថា ពីរដងនៅចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ មែនទេ?

**ឆ៖** បាទ មែនហើយបាទ។

**ស៖** លោកសាក្សី នៅពេលអ្នកស៊ើបអង្កេតតុលាការបានស្តាប់ចម្លើយលោក កាលពីឆ្នាំ២០០៨ លោកមិនបាននិយាយដូចនេះទេ។ លោកនិយាយផ្សេងពីនេះវិញ លោក-- ខ្ញុំសូមដកស្រង់នៅទំព័រទី៦ ជាភាសាបារាំង ERN 00235335, ភាសាអង់គ្លេស 00235129, ជាភាសាខ្មែរ 00231103។ លោកបាននិយាយថា៖ "កិច្ចប្រជុំឃោឌានោះ គឺថាពីរដងក្នុងមួយឆ្នាំ គឺថា មានលើសពីប្រាំមួយទៅទៀត ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"។ អ៊ីចឹងតើយ៉ាងម៉េចដែរ វាមានភាពខុសគ្នានេះ? តើការពិតយ៉ាងម៉េចដែរ?

[០៩:៥៦:៥៣]

**ឆ៖** បាទខ្ញុំសូមពិភាក្សាជាមួយមេធាវីសិនបាទ។

**ប្រធានអង្គជំនុំ៖**

បាទ កុំអាលទាន់ឆ្លើយ សូម-- សាក្សីកុំអាលទាន់ឆ្លើយតបទៅនឹងសំណួរ ចាំស្តាប់សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំគិតថា ប្រហែលជាមានការខុសគ្នា នៅក្នុងភាសាៗផ្សេងគ្នា។ ខ្ញុំអានតបនូវចម្លើយតបជាភាសាអង់គ្លេស ចំពោះខ្ញុំវាមានន័យថា ការប្រជុំហ្នឹងវាកើតឡើងជាញឹកញាប់លើសពីអ្វីដែលគាត់

និយាយ ហើយពីព្រឹកនេះគាត់បាននិយាយថា គាត់ទៅទីនោះពីរដង។ ដូច្នេះ ខ្ញុំគិតថា ប្រហែលជាមានភាពខុសគ្នា រវាងការដែលគាត់ចូលរួមកិច្ចប្រជុំ និងការដែលកិច្ចប្រជុំហ្នឹងរៀបចំ។ ដូច្នេះ ខ្ញុំមិនចង់ឲ្យសាក្សី គាត់មានការច្រឡំ។ ដូច្នេះ ចង់ឲ្យមានការបញ្ជាក់បន្ថែមទៅលើបញ្ហានេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសេចក្ដីកត់សម្គាល់របស់លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ត្រឹមត្រូវ។ បរិបទនេះខុសគ្នារវាងសំណួរ ដែលបានតាំងសួរនៅក្នុងកំណត់ហេតុ ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យចៅក្រមស៊ើបអង្កេត ដែលបានសួរ ហើយនិងសំណួរដែលមេធាវីបានសួរ។ សំណួរនេះខុសគ្នាឆ្ងាយណាស់។ សំណួរមួយសួរថា “តើកិច្ចប្រជុំធំដែលធ្វើនៅស្ដាតអូឡាំពិកហ្នឹង វាញឹកញាប់ប៉ុនណាដែរ?” ឯសំណួរ អម្បាញ់មិញនេះ លោកតាំងសំណួរថា “តើគាត់ធ្លាប់បានទៅចូលរួមជាកងការពារនៅក្នុងកិច្ចប្រជុំនៅស្ដាតអូឡាំពិកហ្នឹងប៉ុន្មានដងនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ?” អ៊ីចឹងសំណួរនេះខុសគ្នាឆ្ងាយ មិនអាចយកមកប្រៀបធៀបគ្នាបានឡើយ។ សូមលោករៀបចំនូវសំណួរលោកឲ្យបានត្រឹមត្រូវ ដើម្បីងាយយល់ស្ដាប់បាន ហើយនិងអាចឆ្លើយតបចំបញ្ហា។

[០៩:៥៩:០២]

**លោក អាកទូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោកសាក្សីនៅក្នុងចន្លោះឆ្នាំ៧៥ ទៅដល់ឆ្នាំ៧៩ តើលោកជាប្រធានអង្គរក្សរបស់ ប៉ុល ពត មែនទេ?

**លោក អឿន តាំ៖**

**ឆ៖** បាទ ខ្ញុំនៃប្រធានក្រុមការពារ កងការពារបាទ។ ដូចជា និយាយឲ្យចំទៅគឺថា ជាអង្គរក្សដែរ។ អង្គរក្សនេះគឺ ទៅណាមកណា គេហៅទៅជាប់ដែរបាទ។

**ស៖** តើលោកមានកូនចៅប៉ុន្មាននាក់ដែរ ជាកងការពារនុ៎ង?

**ឆ៖** បាទ ខ្ញុំមានកូនចៅ ១០នាក់។ បាទ ក្នុងក្រុមខ្ញុំមាន ១០នាក់។

**ស៖** ដូច្នេះ តើយើងអាចនិយាយបានទេថាក្នុងឋានៈជាមេនៃកងការពារជិត ប៉ុល ពត នោះលោកត្រូវបានគេជូនដំណឹងអំពីការផ្លាស់ទីរបស់លោក ប៉ុល ពត ទាំងអស់។ តើអ៊ីចឹងមែនទេ? អាច

និយាយអ៊ីចឹងបានទេ?

**ឆ៖** បាទ សូមបញ្ជាក់ម្តងទៀត ចាំខ្ញុំពិភាក្សាជាមួយមេធាវីបាទ។

[១០:០០:៥៦]

*(សាក្សីពិភាក្សាជាមួយមេធាវីប្រឹក្សា)*

[១០:០១:៤៧]

**ស៖** លោកសាក្សី លោកជាមេអង្គរក្សជិតដិតរបស់លោក ប៉ុល ពត នៅចន្លោះឆ្នាំ១៩៧៥ ដល់ ៧៩។ តើក្នុងឋានៈនេះលោកត្រូវបានទទួលជូនដំណឹងអំពីការធ្វើដំណើររបស់ ប៉ុល ពត នៅក្នុងរបបនេះ តើមែនទេ?

**ឆ៖** បាទ គឺមែនហើយបាទ។

**ស៖** ទោះបីជាថា មិនមែនលោកផ្ទាល់ដែលជាអ្នកជូនដំណើរអមដំណើរ ប៉ុល ពត ពេលដែលគាត់ធ្វើដំណើរ ឬក៏យ៉ាងហោចក៏ជាកូនចៅរបស់លោកម្នាក់ដែលជាអ្នកជូនដំណើរគាត់ដែរ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺអ៊ីចឹងមែនហើយបាទ។

**ស៖** ដូច្នេះ គឺថាលោកត្រូវតែមានលទ្ធភាពអាចនិយាយបានថា ប្រាប់យើងថា តើ ប៉ុល ពត ទៅស្ពាតអូឡាំពិកប៉ុន្មានដងចន្លោះឆ្នាំ១៩៧៥ ដល់ ៧៩ ទោះបីថាមិនមែនលោកផ្ទាល់ដែលថា ទៅ អ្នកជូនដំណើររាល់ពេលគាត់ធ្វើដំណើរទៅស្ពាតអូឡាំពិកក៏ដោយ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែនហើយបាទ។

[១០:០៣:៣៧]

**ស៖** បាទ ដូច្នេះទោះបីជាជាមួយលោក ឬក៏ជាមួយកូនចៅណាម្នាក់របស់លោកក៏ដោយ គឺចន្លោះនៅឆ្នាំ១៩៧៥ និង ១៩៧៩ តើ ប៉ុល ពត ទៅស្ពាតអូឡាំពិកប៉ុន្មានដង ដើម្បីធ្វើកិច្ចប្រជុំយោធា?

**ឆ៖** បាទ ខ្ញុំអត់ចាំទេបាទ។

**ស៖** តើអង្កាល់នៅឆ្នាំ២០០៨ ដែលៗអ្នកស៊ើបអង្កេតតុលាការយើងនេះបានស្តាប់ចម្លើយលោកនោះ តើលោកចាំទេ ចាំកាលរឿងហេតុដែលកើតឡើងនៅសម័យខ្មែរក្រហមនោះទេ?

**ឆ៖** បាទ ខ្ញុំអង្កាល់នុ៎ង ដូចនែ៎ លោកមកសម្ភាសខ្ញុំនោះ ក៏ខ្ញុំមិនចាំទេបាទ។ យូរហើយ។

**ស៖** បាទ ខ្ញុំអាចយល់ ប៉ុន្តែតើលោកអាចឆ្លើយសំណួរ តបនឹងសំណួរខ្ញុំបានទេ។ ឥឡូវនេះ

ខ្ញុំសួរម្តងទៀត។ លោកនិយាយមិនចាំអំពីចំនួនកិច្ចប្រជុំឃោធា ដែល ប៉ុល ពត បានចូលរួមនោះទេ នៅស្តាតអូឡាំពិក។ ហើយសំណួររបស់ខ្ញុំ គឺចង់ដឹងថា តើនៅឆ្នាំ២០០៨ លោកបានចាំពីកិច្ចប្រជុំហ្នឹងដែរឬទេ?

**ផ៖** សូមលោក១បញ្ជាក់អំពីនេះ តាមការចម្លើយរបស់នៅក្នុងកិច្ចការសម្ភាស អាហ្នឹងខ្ញុំចាំ។ បើថាឲ្យខ្ញុំឆ្លើយក្រៅពីនោះ គឺខ្ញុំអត់ចាំទេ បើថាមើលតាមនៃការសម្ភាស ខ្ញុំអាចឃើញក្នុងថ្ងៃណាប៉ុន្មានថ្ងៃៗ ខ្ញុំចាំ។ ពេលដែលសួរលាតអ៊ីចឹងទៅ ខ្ញុំមិនចាំទេបាទ។

**ស៖** បាទ លោកសាក្សី ខ្ញុំនឹងធ្វើយ៉ាងដូច្នេះ។ គឺលេខ 00235333 ជាសំណៅ ជាភាសាបារាំង ហើយលេខ ដូចលេខដែលខ្ញុំបានជូនអម្បាញ់មិញហ្នឹងដែរ។ សំណួររបស់អ្នកស៊ើបអង្កេត៖ "កិច្ចប្រជុំនៅស្តាតអូឡាំពិក កើតមានញឹកញាប់ទេ? ចម្លើយ៖ មិនញឹកញាប់ទេ ពេលខ្លះពីរដងក្នុងមួយឆ្នាំ ហើយអ្នកដែលកោះហៅការប្រជុំ គឺ ប៉ុល ពត។ ខ្ញុំចាំថា សុន សេន បានចូលរួមក្នុងការប្រជុំនោះដែរ។ ឯមេដឹកនាំផ្សេងទៀត ដូច អៀង សារី, នួន ជា, ខៀវ សំផន ខ្ញុំមិនឃើញចូលរួមក្នុងការប្រជុំនោះទេ"។ បាទ ខ្ញុំសូមបញ្ចប់ការដកស្រង់។

បាទ នេះជាអ្វីដែលលោកបាននិយាយ នៅពេលដែលលោកផ្តល់ចម្លើយទាក់ទងទៅនឹងកិច្ចប្រជុំនោះ។ តើលោកចាំទេ ចាំចម្លើយរបស់លោកនេះទេ?

[១០:០៧:៣១]

**ផ៖** បាទ គឺចាំ ដូចបានលោកបានអានជូនអំមិញ គឺខ្ញុំចាំ។ ហើយបើថាបញ្ជាក់មួយៗ ខ្ញុំចាំច្បាស់ថែមទៀត បាទ។ ក្នុងមួយឆ្នាំពីរដង បាទ។ ក្នុងការប្រជុំនៅអូឡាំពិក។

**ស៖** លោកសាក្សី ដូច្នេះ ទាក់ទងនឹងភាពញឹកញាប់នៃកិច្ចប្រជុំឃោធាទាំងអស់នេះ លោកបញ្ជាក់ថា-- លោកបញ្ជាក់អំពីអ្វីដែលលោកបាននិយាយនៅឆ្នាំ២០០៨ នោះ គឺថាកិច្ចប្រជុំនេះ ប្រព្រឹត្តទៅពីរដងក្នុងមួយឆ្នាំ តើអ៊ីចឹងមែនទេ? លោករក្សាចម្លើយហ្នឹងមែនទេ?

**ផ៖** បាទ ខ្ញុំសូមរក្សាចម្លើយហ្នឹង បាទ។

**ស៖** ការលំបាករបស់ខ្ញុំ លោកសាក្សី គឺថានៅទំព័របន្ទាប់ នៃឯកសារស្តាប់ចម្លើយរបស់លោកនេះ ដែលចុះនៅថ្ងៃទី០៩ តុលា ឆ្នាំ២០០៨ អ្នកស៊ើបអង្កេតសួរលោកដូចតទៅនេះ ហើយខ្ញុំសូមអានចម្លើយលោកផងដែរ ភ្ជាប់គ្នា។ "សំណួរ៖ ក្រៅពីកិច្ចប្រជុំទៀងទាត់នោះ តើមានប្រជុំនៅកន្លែងណាទៀតទេ? ចម្លើយរបស់លោក៖ មានតែនៅអូឡាំពិក ក្នុងរវាងបីបួនខែម្តង ដែលការប្រជុំឃោធាទាំងអស់

នេះ ដែលដឹកនាំដោយ ប៉ុល ពត"។ បាទ ខ្ញុំសូមបញ្ចប់ការដកស្រង់។ បាទ ឥឡូវនេះ យើងសង្កេតឃើញថា គ្រាន់តែគំលាតគ្នាតែពីរ មួយទំព័រហ្នឹងគឺថាវាមានភាពខុសគ្នាពី ដល់ពីរដងនោះ គម្លាតរយៈពេលនៃការប្រជុំទាំងអស់នេះ។ គឺថានៅក្នុងការស្ដាប់ចម្លើយរបស់លោកតែមួយនុ៎ង មានឃ្លាតគ្នាដល់ទៅពីរដង ខុសគ្នាពីរដងនៃភាពញឹកញាប់ហ្នឹង។ អ៊ីចឹងតើលោកអាចពន្យល់ពីភាពខុសគ្នានេះបានដែរឬទេ?

[១០:១០:១៥]

**ឆ៖** បាទ ខ្ញុំនិយាយខាងដើមថា ខ្ញុំភ្លេចហ្នឹង អត់ចាំ។ ហើយបើថា បញ្ជាក់ពីការសម្ភាស ខ្ញុំសូមយកតាមការសម្ភាសហ្នឹង។ ប៉ុន្តែឲ្យខ្ញុំនិយាយហូរហែមក ខ្ញុំអត់ចាំទេបាទ។

**ស៖** ដូច្នេះ លោកៗរក្សាចម្លើយណាទៅ ទាក់ទងនឹងកិច្ចប្រជុំនៅស្ដាតអូឡាំពិកនេះ? ចង់រក្សាចម្លើយថា ការប្រជុំនេះប្រព្រឹត្តទៅពីរដងមួយឆ្នាំ ឬក៏ចង់និយាយថា កិច្ចប្រជុំនេះប្រព្រឹត្តទៅពីបីទៅបួនដងក្នុងមួយឆ្នាំ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមធ្វើការជំទាស់ ពីព្រោះថាជា-- ចំពោះសាក្សីនោះគាត់ពិបាកយល់សំណួរណាស់ ព្រោះថាសាក្សីមិនដែលនិយាយថា ពីរដងមួយឆ្នាំទេ។ គាត់ប្រើពាក្យថា "ជួនកាល"។ អ៊ីចឹងយើងគួរតែជឿជាក់លើសក្ខីកម្មគាត់ខ្លះដែរ ព្រោះថា គាត់និយាយថា ជួនកាលពីរឆ្នាំម្ដង។ អ៊ីចឹងបានន័យថា វាអាចខ្លះហ្នឹង ជួនកាលទៅវាបីដងមួយឆ្នាំដែរ ព្រោះមានពាក្យថា "ជួនកាល"។

[១០:១២:១០]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកសាក្សី លោកយល់យ៉ាងម៉េចដែរលោកសាក្សី?

**លោក អឿន តាន៖**

**ឆ៖** ខ្ញុំយល់ដូចមេធាវីបានបញ្ជាក់អំមិញហើយថា ជួន ខ្ញុំប្រើពាក្យ "ជួនកាល" អ៊ីចឹងទៅ។ ជួនកាលពីរដង ជួនកាលពីរទៅបីដងអ៊ីចឹងទៅ។ ខ្ញុំប្រើពាក្យអ៊ីចឹងបាទ។

**សៈ** នៅពេលដែលលោកបានជួបអ្នកស៊ើបអង្កេតនៃតុលាការយើងនៅឆ្នាំ២០០៨ តើលោកមានភ័យខ្លាចពួកគាត់ចាប់ខ្លួនលោកទេកាលនុ៎ង?

**ឆៈ** បាទពីមុនៗខ្លាចដែរ។ ដល់ពេលក្រោយមក គឺថាគេពន្យល់ ជាពិសេសគឺមេមកសម្ភាសខ្ញុំថាកុំខ្លាច ខ្ញុំមកសម្ភាសនេះ ដើម្បីតែយកការពិត ព្រោះលោកជាសាក្សី ដែលលោកបានពន្យល់ខ្ញុំអ៊ីចឹង។ ដែពេលនោះ ខ្ញុំលែងខ្លាច។ បើពេលមុនក៏ខ្លាច ព្រោះខ្ញុំមិនទាន់យល់។ ដល់គេមកសម្ភាសអ៊ីណោះទៅគេពន្យល់ហេតុផលអ៊ីចឹងទៅ ខ្ញុំអត់ខ្លាច ធម្មតាវិញបាទ។

[១០:១៣:៤៥]

**សៈ** តើការភ័យខ្លាចរបស់លោក ដែលថាលោកពីមុនមកលោកធ្លាប់ភ័យនេះ ការភ័យខ្លាចនេះវាអាចជះឥទ្ធិពលទៅចម្លើយរបស់លោកចំពោះមុខអ្នកស៊ើបអង្កេតទាំងអស់នេះដែរឬទេ ទោះបីជាមានការព្យាយាមលួងលោមលោក ធ្វើឱ្យលោកឈប់ភ័យនោះក៏ដោយ?

**ឆៈ** បាទ អត់មានទេបាទ។

**សៈ** ឥឡូវនេះខ្ញុំសូមនិយាយអំពីប្រធានបទមួយទៀត ដែលទាក់ទងនឹងចម្ងាយសុវត្ថិភាព ដែលលោកត្រូវតែគោរពរវាងលោក ហើយនិងលោក ប៉ុល ពត នៅពេលដែលលោកធ្វើការយាមកាមគាត់។ នៅឆ្នាំ-- នៅខែតុលា ឆ្នាំ២០០៨ ហើយម្សិលមិញនេះក៏ដោយ លោកបានពន្យល់ថា លោកមិនអាចឮការសន្ទនារបស់លោក ប៉ុល ពត ជាមួយបុគ្គលផ្សេងទៀតបាននោះទេ ពីព្រោះលោកត្រូវគោរពចម្ងាយសុវត្ថិភាពពី១០ទៅ២០ម៉ែត្រ ពី ប៉ុល ពត នៅពេលដែលលោក ប៉ុល ពត នេះត្រូវពិភាក្សាគ្នាជាមួយអ្នកផ្សេង។ តើពិតជាអ៊ីចឹងមែនឬទេ?

**ឆៈ** បាទ គឺពិតអ៊ីចឹងមែនបាទ។

**សៈ** លោកបាននិយាយប្រាប់យើងផងដែរថា លោកទទួលបន្ទុកការពារសុវត្ថិភាពលោក ប៉ុល ពត ចាប់ពីឆ្នាំ១៩៧០។ តើចាប់ពីពេលនោះមក លោកត្រូវគោរពចម្ងាយសុវត្ថិភាពនេះដែរឬទេ?

**ឆៈ** បាទ ពេលនោះគឺថាតាមបញ្ជា គឺថាៗឱ្យ២០ម៉ែត្រ គឺនៅ២០ម៉ែត្រអ៊ីចឹង តែបើថាយើងដើរជិតក្បែរៗគេធ្វើការ គេស្តីឱ្យយើងបាទ។

[១០:១៦:២៦]

**សៈ** ហើយអ្នកកងការពារផ្សេងទៀតរបស់ ប៉ុល ពត នោះ ត្រូវអនុវត្តវិន័យនេះដែរឬទេ?

**ឆៈ** បាទ គឺអនុវត្តវិន័យទាំងអស់គ្នាបាទ។

**ស៖** ចាប់ពីឆ្នាំ១៩៧០ ហ្នឹងដូចគ្នាដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គឺដូចគ្នាបាទ អត់មានកែប្រែទេ គឺដូចគ្នាៗតែម្តងបាទ។

**ស៖** តើលោកដឹងដែរឬទេថា កងការពារផ្សេងទៀត កងការពាររបស់អ្នកដឹកនាំផ្សេងទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ អនុវត្តវិន័យដូចគ្នា?

**ឆ៖** បាទ គឺអ្នកដឹកនាំផ្សេងៗទៀត គឺថាកងការពារគឺថាគោរពវិន័យដូចតែគ្នា។

**ស៖** នៅ-- បាទខ្ញុំសូមប្តូរប្រធានបទលោកសាក្សី។ នៅពេលដែលលោកបានជួបអ្នកស៊ើអង្កេតតុលាការយើងនៅខែតុលា ឆ្នាំ២០០៨ តើការពិភាក្សារបស់លោកហ្នឹង មានរយៈពេលប៉ុន្មានដែរ?

**ឆ៖** បាទខ្ញុំមិនសូវចាំទេបាទ។ ឲ្យតែសម្ភាសចប់ទៅ គឺចប់ហើយ។ ខ្ញុំគិតពីការងារធ្វើចម្ការ។ តែប៉ុន្មានថ្ងៃៗ ខ្ញុំភ្លេចអស់ហើយបាទ។

**ស៖** ការពិភាក្សាគ្នាហ្នឹងអស់រយៈពេលពេញមួយថ្ងៃ ឬក៏តែមួយព្រឹកទេ ឬក៏មួយព្រឹកបូកមួយរសៀល ឬក៏លើសពីហ្នឹងទៅទៀត?

[១០:១៨:៤៩]

**ឆ៖** កាលនុ៎ងដូចពេញមួយថ្ងៃ បាទ។

**ស៖** តើកិច្ចសម្ភាសន៍ហ្នឹងមានរយៈពេលលើសពីមួយថ្ងៃ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំមិនចងចាំទេបាទ ព្រោះវាយូរហើយ មិនដឹងប៉ុន្មានថ្ងៃៗ ខ្ញុំមិនចងចាំទេ។ តាមការប៉ាន់ស្មានគឺថាដូចមួយថ្ងៃទេពេលនុ៎ង។ សូមលោកបញ្ជាក់តាមកិច្ចការសម្ភាសទៅ ឃើញហើយ។ ខែប៉ុណ្ណោះៗទៅ ឃើញ បាទ។

**ស៖** បាទ លោកនិយាយថា អ៊ូ! យូរ រយៈពេលកន្លងផុតយូរមកហើយ-- វារយៈពេលតែបួនឆ្នាំសោះហ្នឹង ហើយខ្ញុំគិតថាដូចវាមិនយូរអីប៉ុន្មានទេ បួនឆ្នាំ។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់ដោយសារថា សាក្សីបានឆ្លើយហើយថា ការចងចាំរបស់គាត់នោះ គឺថា ហើយបើសិនជាផ្តោតទៅលើថាការសម្ភាសនោះយូរប៉ុនណា អីប៉ុនណា គឺថាអាចគាត់ឆ្លើយរួចហើយ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ ជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងចម្លើយដែលមិនចាំបាច់។ អង្គជំនុំជម្រះត្រូវការស្តាប់នេះ ចំពោះសំណួររបស់មេធាវីការពារក្តីនេះទេ។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** លោកសាក្សី មានវគ្គពីរនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក នៅថ្ងៃទី០៩ តុលា ឆ្នាំ២០០៨ ដែលធ្វើឱ្យខ្ញុំភ្ញាក់ផ្អើល ធ្វើឱ្យខ្ញុំឆ្ងល់។ ខ្ញុំនឹងពន្យល់ថា ហេតុអ្វីបានខ្ញុំឆ្ងល់។ វគ្គទីមួយ គឺការចេញពីសំណួររបស់អ្នកស៊ើបអង្កេតលើការប្រជុំនៅស្ដាតអូរឡាំពិក គឺលេខ ដូចលេខ ERN ដូចលេខដែលខ្ញុំបានជម្រាបជូនអម្បាញ់មិញអ៊ីចឹង។

អ្នកស៊ើបអង្កេតបានសរសេរ បាទខ្ញុំសូមដកស្រង់៖ “លោកបានប្រាប់យើងថា មានការប្រជុំនៅស្ដាតអូរឡាំពិក តើលោកដឹងពីរបៀបវារៈនៃកិច្ចប្រជុំនេះដែរឬទេ?” សូមបញ្ចប់ការដកស្រង់។ ក៏ប៉ុន្តែពេលនោះជាក់លាក់តែម្ដង នៅពេលដែលលោកផ្ដល់សក្ខីកម្មជាលាយលក្ខណ៍អក្សរ ពេលនោះលោកមិនទាន់បាននិយាយអំពីការប្រជុំនៅស្ដាតអូរឡាំពិកនោះទេ ហើយវាមានភាពដូចគួរឱ្យឆ្ងល់នេះ វាកើតឡើងម្ដងទៀត នៅលេខ ERN ជាភាសាបារាំង គឺ 00235340, ជាភាសាអង់គ្លេស 00235134 ហើយនិងជាភាសាខ្មែរ 00231810 និងភាពគួរឱ្យចម្លែក គួរឱ្យឆ្ងល់នេះ កើតមានឡើងនៅពេលដែលអ្នកស៊ើបអង្កេតសួរសំណួរលោក ទាក់ទងទៅនឹងការធ្វើដំណើររបស់លោក ប៉ុល ពត ទៅខេត្ត។

[១០:២៣:១២]

ហើយអ្នកស៊ើបអង្កេតសួរលោកថា លោកបាននិយាយថា លោកបានជូនដំណើរ ប៉ុល ពត ទៅតាមតំបន់ភូមិភាគចន្លោះឆ្នាំ១៩៧៥-៧៦។ ក៏ប៉ុន្តែនៅទំព័របន្ទាប់មកទៀត អ៊ំ! ខាងមុខហ្នឹងមួយទំព័រនៅក្នុងកំណត់ហេតុដដែលហ្នឹង លោកនិយាយពីការធ្វើដំណើររបស់លោក ប៉ុល ពត ក៏ប៉ុន្តែលោកមិនបានផ្ដល់កាលបរិច្ឆេទទេ។ ខ្ញុំដឹងថា បញ្ហានេះប្រហែលជាស្មុគស្មាញចំពោះលោក យើងខ្ញុំព្យាយាមធ្វើឱ្យស្រួលនិយាយឱ្យស្រួលស្ដាប់។ យើងមាន-- តុលាការយើងនេះមានខ្សែអាត់ ពី-- នៃការពិភាក្សារបស់លោក ជាមួយអ្នកស៊ើបអង្កេតនោះ គឺថាឯកសារ D107/2R ខ្ញុំបានស្ដាប់ខ្សែអាត់នុ៎ង។ នៅថ្ងៃទី០៩ តុលា ឆ្នាំ២០០៨ ជាមួយអ្នកស៊ើបអង្កេតនៃតុលាការយើងនេះ ហើយខ្ញុំឃើញថាមានបីកន្លែង អ៊ំ! បួនកន្លែង លោកបាន ហើយនិយាយ និងអ្នកស៊ើបអង្កេតក៏និយាយផងដែរ អំពីការពិភាក្សារបស់លោកពីថ្ងៃមុន និងមុនមួយថ្ងៃ គឺថាថ្ងៃទី០៨ តុលា ឆ្នាំ២០០៨។ ខ្ញុំសូមដកស្រង់ ដើម្បីជាប្រតិចារឹកវគ្គនៃខ្សែអាត់ហ្នឹង ដែលនៅវគ្គហ្នឹង យើងឃើញថា មានការនិយាយយោងទៅការពិភាក្សាគ្នាមុនហ្នឹងមួយថ្ងៃ គឺនៅនាទីទីប្រាំ សែសិបប្រាំសឹហ្គុង ជាមួយសំណួរ-- ដែលអ្នកស៊ើបអង្កេតសួរថា “ខ្ញុំនឹងចោទសំណួរដែលខ្ញុំសួរលោកកាលពីម្សិលមិញ”។ នៅនាទីទីប្រាំ ប្រាំមួយវិនាទី អ្នកស៊ើបអង្កេតសួរ “ខ្ញុំចង់

ឲ្យលោកត្រឡប់និយាយអំពីការម្សិលមិញ ព្រោះថា ម្សិលមិញខ្ញុំអត់បានថតលោកទេ ថតសំឡេងលោកទេ។" ហើយលោកបានឆ្លើយ "យល់ព្រម"។ ហើយករណីហ្នឹងមានដែរ គឺថានៅនាទី--

[១០:២៥:៥៥]

**ប្រធានអង្គជំនុំ៖**

លោកមានបំណងធ្វើអី? លោកតាំងសំណួរដេញដោលចំពោះសាក្សី ឬក៏លោកធ្វើយ៉ាងម៉េចវេទិកានេះ? យើងផ្តល់វេទិកាឲ្យលោក លោកធ្វើការតាំងសំណួរដេញដោលចំពោះសាក្សី ហើយលោកដូចជា លេងមួយឆ្អែតមកនេះ ដូចជាសូម្បីតែអង្គជំនុំជម្រះខ្លួនឯងស្តាប់មិនបានផងនេះ។

លោកធ្វើសេចក្តីសន្និដ្ឋាន ឬយ៉ាងម៉េច? លោកកែសម្រួលនូវនីតិវិធីនៃការសួរដេញដោលនេះឡើងវិញ ប្រសិនបើលោកមានបំណងធ្វើជាសេចក្តីសន្និដ្ឋាន។ សូមលោកពិនិត្យមើល និងអនុវត្តឲ្យបានត្រឹមត្រូវ តាមបទប្បញ្ញត្តិនៃវិធាន៩២ នៃវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារ។ យើងមិនអនុញ្ញាតឲ្យលោកធ្វើដូច្នេះទេ។

[១០:២៦:៥៥]

**លោក អាកទ្វរ វែកគែន៖**

ប៉ុន្តែខ្ញុំមិនមែនកំពុងធ្វើសេចក្តីសន្និដ្ឋានទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

យើងមិនឲ្យអ្នកឯងតទៅទៀតទេ មិនឲ្យធ្វើទេ។ ឥឡូវលោកត្រូវតាំងសំណួរអីធ្វើឲ្យច្បាស់។ បើសួរវែងយ៉ាងនេះ ស្តាប់មិនយល់ទេ។ តាំងសំណួរយើងប្រាប់ហើយ ឲ្យខ្លី ឲ្យច្បាស់ ហើយគោលដៅដែលត្រូវទទួល ការសួរ ស្តាប់នូវសំណួររបស់លោកយល់ ច្បាស់ ហើយឆ្លើយឲ្យចំទៅនឹងសំណួរ។ មិនមែនជ្រើសរើសយកសំណួរ ដែលសួរធ្វើឲ្យភាគីដែលពាក់ព័ន្ធស្តាប់មិនយល់ផង ទម្រាំតែសាក្សីដែលមានកម្រិតវប្បធម៌របៀបនេះ មិនយល់បានផង តើឆ្លើយតបតាមរបៀបណា ទៅនឹងខ្លឹមសារនៃសំណួរ។ តើវាមានផលប្រយោជន៍អ្វីក្នុងការស្វែងរកការពិតដែរឬទេ?

[១០:២៧:៤៤]

លោកអាចប្តូរសំណួរ ឬក៏តាំងសំណួរជាថ្មី ឲ្យបានច្បាស់លាស់ជាក់ច្បាស់ បើសិនជាការសេចក្តីសន្និដ្ឋាន លោកធ្វើ សូមអនុវត្តតាមវិធាន៩២ នៃវិធានផ្ទៃក្នុង ដែលកំពុងតែធរមាន ហើយនិងកំពុងតែអនុវត្តបច្ចុប្បន្ននេះ យើងបានប្រាប់ម្សិលមិញរួចហើយ។

ការដាក់សេចក្តីសន្និដ្ឋានរហូតដល់ការបិទពិភាក្សាដេញដោល រហូតទល់ពេលនឹងការបិទកិច្ចពិភាក្សាដេញដោល ភាគីអាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះ ត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទទទួលសេចក្តីសន្និដ្ឋាននេះ ហើយត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។

[១០:២៨:៥៣]

**លោក អាកទ្បូរ វែកគែន៖**

លោកប្រធាន ខ្ញុំនឹងចោទសួរឲ្យខ្លីៗលោកប្រធាន ទោះបីជាខ្ញុំគិតថា លោកប្រហែលជាយល់ពីជំហរទិសដៅរបស់ខ្ញុំហើយ គឺថា យើងចង់ដឹងពីភាពស្មោះត្រង់របស់សាក្សី។

**សួរដោយលោក អាកទ្បូរ វែកគែន៖**

**ស៖** លោកសាក្សីនៅក្នុងខ្សែអាត់ នៃកិច្ចសម្ភាសន៍របស់លោកជាមួយសហព្រះរាជអាជ្ញា កាលពីថ្ងៃទី០៩ តុលា ឆ្នាំ២០០៩ មានប្អូនកន្លែង-- ប្អូនដង លោក ហើយនិងអ្នកស៊ើបអង្កេតបាននិយាយយោងទៅការពិភាក្សាគ្នាមុននុ៎ងមួយថ្ងៃ គឺថ្ងៃទី០៨ តុលា ឆ្នាំ២០០៩។ តើលោកចាំទេ ចាំ-- ២០០៨ *(សូមទោសអ្នកបកប្រែសូមកែប្រែ)* តើលោកចាំទេ ការយោងទៅ ប្អូនដងនេះ?

**លោក អឿន តាន៖**

**ឆ៖** បាទ ខ្ញុំមិនចាំទេបាទ ព្រោះការសម្ភាស គេសម្ភាសពេលណាៗ ក៏ខ្ញុំមិនចាំទេ បើគេសម្ភាសខ្ញុំចេះតែនិយាយទៅ បើថាឲ្យចាំថ្ងៃខែប៉ុន្មានដងៗ ខ្ញុំអត់ចាំទេ ពីព្រោះតាមការក្តាប់សំណួរសួរដូចលោកប្រធានបានបញ្ជាក់ហើយថា បើថាសួរហួរហែមកវែងមកគឺថា ខ្ញុំក្តាប់មិនបានទេបាទ។ ព្រោះខ្ញុំដូចលោកប្រធានបញ្ជាក់ថា ខ្ញុំកម្រិតវប្បធម៌វាតិច វាមិនចេះ ដល់សួរសំណួរហួរហែវែងឆ្ងាយទៅខ្ញុំពិបាកឆ្លើយដែរបាទ។ សូមសួរដោយខ្លីៗបាទ។

[១០:៣០:៤០]

**ស៖** ម្សិលមិញ ព្រឹកម្សិលមិញនៅពេលដែលចាប់ផ្តើមផ្តល់សក្ខីកម្ម ប្រធានអង្គជំនុំជម្រះបានសួរលោកថា តើលោកជួបអ្នកស៊ើបអង្កេតតុលាការនេះប៉ុន្មានដង? លោកបានឆ្លើយប្រាប់គាត់ថា បានជួបតែម្តងទេ តើលោកចាំទេ ចម្លើយលោកឆ្លើយម្សិលមិញដែលលោកឆ្លើយតបទៅលោកប្រធាន?

**ឆ៖** បាទ បញ្ជាក់អ៊ីចឹងទៅគឺខ្ញុំចាំបាទ។ ដូចបានបញ្ជាក់អំមិញ ខ្ញុំចាំបាទ។

**ស៖** លោក បើសិនជាខ្ញុំអះអាងថាលោកបានជួបអ្នកស៊ើបអង្កេតពីរដង ហើយពីរឆ្នាំពីរខុសគ្នា

ហ្នឹង បាទ លោក បានន័យថាខ្ញុំច្រឡំ ឬក៏យ៉ាងម៉េច បើខ្ញុំអះអាងថាលោកបានជួបអ្នកស៊ើបអង្កេតពីរដង ហើយឆ្នាំពីរខុសគ្នា?

[១០:៣១:៣២]

**ឆ៖** ឥឡូវសូមលោកមើលតាមកិច្ចការសម្ភាសទៅប៉ុន្មានដងៗ ខ្ញុំក៏អាចយកជាផ្លូវការមកហ្នឹង ព្រោះឲ្យខ្ញុំនិយាយសរុបសាឡើង ដូចថាខ្ញុំមិនចាំ ដូចខ្ញុំបញ្ជាក់ខាងដើម ខ្ញុំមិនចាំទេបាទ។ ដូច្នេះយកតាមការសម្ភាសប៉ុន្មានដងៗ អ៊ីចឹងទៅ ដូចថាខ្ញុំឯកភាព។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោង ដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការផ្តល់កន្លែងសម្រាកសមរម្យនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោង ដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥០ នាទី)*

[១០:៥០:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ប្រសិនបើមាននៅសេសសល់សំណួរ។ ហើយអាចបញ្ជាក់បានទេ តើក្រុមមេធាវីហ្នឹង ត្រូវការពេលវេលាប៉ុន្មានទៀតដែរ?

**លោក អាកទ្បូរ វែកគែន៖**

លោកប្រធាន ប្រហែលជាជាងដប់ប្រាំនាទីអីទៀតទេ លោកប្រធាន។

លោកសាក្សី-- សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** លោកសាក្សី មុនពេលឈប់សម្រាកអម្បាញ់មិញនេះ ខ្ញុំបានសួរលោកថា តើលោកចងចាំទេ ថាលោកបានជួបអ្នកស៊ើបអង្កេតតុលាការ ក្រៅពីឆ្នាំ២០០៨ ហើយលោកឆ្លើយថា លោកទុកចិត្តលើខ្ញុំ ឲ្យខ្ញុំពិនិត្យមើលកិច្ចសម្ភាសន៍ហ្នឹងទៅ ដែលគាត់-- ដែលលោកបានសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតនោះ នៅ-- ដែលមានអាចថាមានថ្ងៃណាមួយទៀត។ ប៉ុន្តែខ្ញុំសូមអនុញ្ញាតសង្កត់ធ្ងន់នៅលើចំណុចនេះ ពីព្រោះថាវាមានសារៈសំខាន់ណាស់ ចំពោះខ្ញុំ ក្នុងការដឹងឲ្យបានច្បាស់អំពីស្ថានភាពនៃការចងចាំរបស់លោក។

[១០:៥២:៤៣]

ជាពិសេស ខ្ញុំចង់ដឹង ថាតើលោកអាចចងចាំអំពីហេតុការណ៍សំខាន់ៗ ឧទាហរណ៍ដូចជាជួបជាមួយអ្នកស៊ើបអង្កេតតុលាការ ដែលបានប្រព្រឹត្តទៅកាលពីប៉ុន្មានឆ្នាំមុននេះ។ ខ្ញុំសូមសួរសំណួរឡើងវិញ តើលោកចាំថា បានជួបជាមួយអ្នកស៊ើបអង្កេតតុលាការនៅត្រឹមតែខែតុលា ឆ្នាំ២០០៨ នេះតែម្តងហ្នឹងទេ ឬក៏មាននៅឆ្នាំណាផ្សេងទៀត?

**លោក អឿន តាន៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ បញ្ហានេះ គឺថាការសង្កេតដែលលោកមក មកសម្ភាសខ្ញុំ តែម្តងបាទ។ បញ្ហាហ្នឹង ខ្ញុំដូចបានបញ្ជាក់ខាងដើមថា ខ្ញុំវាភ្លេចមិនដឹងប៉ុន្មានដងទេ ហើយសូម ខ្ញុំសូមពិភាក្សាជាមួយមេធាវីសិន បាទ។

[១០:៥៤:០០]

*(សាក្សីពិភាក្សាជាមួយមេធាវីប្រឹក្សា)*

[១០:៥៤:០៥]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត។

សូមអរគុណ។ សំណួរត្រូវបានចោទទៅសាក្សី ហើយសាក្សីបានផ្តល់ចម្លើយ។ ដូច្នេះ សាក្សីមិនចាំបាច់ទៅប្រឹក្សាជាមួយមេធាវីនោះឡើយ។ ពីព្រោះថា មេធាវីមិនបានជាអ្វីដែរ គឺគ្រាន់តែសាក្សីផ្តល់ចម្លើយទៅបានហើយ។ ខ្ញុំសូមជំទាស់ទៅលើបញ្ហានេះ។

[១០:៥៥:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី ហើយអង្គជំនុំជម្រះសូមរំឭកដល់សាក្សី និងមេធាវីប្រឹក្សាសាក្សីសាជាថ្មីម្ដងទៀត តាមពិតរឿងនេះ យើងបាននិយាយច្រើនលើកច្រើនសាមកហើយ ថាតួនាទីរបស់មេធាវីប្រឹក្សាសាក្សី គឺរង់ចាំស្ដាប់នូវសំណួរឯណាដែលជាសំណួរឲ្យចម្លើយ ឬសេចក្ដីសន្និ-- ឬក៏ការផ្ដល់អត្ថាធិប្បាយរបស់សាក្សី ដាក់បន្ទុកលើខ្លួនឯង។ នោះទើបជាតួនាទីរបស់មេធាវីប្រឹក្សាសាក្សី ដើម្បីពិគ្រោះពិភាក្សាថាតើគួរឆ្លើយតបទៅនឹងសំណួរបែបនេះ ឬមិនឆ្លើយតប។ ក្រៅពីនេះ គឺមិនមែនមានមុខងារទេ។ ដោយឡែកមុខងារបន្ថែមផ្សេងទៀត គឺអង្គជំនុំជម្រះផ្ដល់ឲ្យដូចជាសាក្សីខ្លះគាត់អន់ត្រចៀកគាត់អន់ភ្នែក យើងគ្រាន់តែឲ្យជួយធ្វើជាសញ្ញាជួយសម្រួលដើម្បីឲ្យនិរន្តរ៍ភាព នៃដំណើរការប្រក្រតីភាពរបស់ដំណើរការពិភាក្សាដេញដោល បានទៅឆាប់រហ័សប៉ុណ្ណោះ។ ដូច្នេះសូមចងចាំនូវចំណុចនេះថាមេធាវីប្រឹក្សាសាក្សី គឺរង់ចាំស្ដាប់នូវសំណួរឯណា ដែលមានការបំណងនៃការឲ្យសាក្សីឆ្លើយ ឬក៏ផ្ដល់ការ-- មតិយោបល់ ឬក៏ធ្វើអត្ថាធិប្បាយណាមួយ ឬច្រើន ដែលមានខ្លឹមសារទំនងជានាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯងប៉ុណ្ណោះ។

[១០:៥៧:០៦]

សាក្សីដូចគ្នា សាក្សីចងចាំបានប៉ុន្មាន ឆ្លើយតាមលទ្ធភាព និងសមត្ថភាពដែលលោកចងចាំទៅបានហើយ។

សូមអញ្ជើញលោកមេធាវីតាំងសំណួរបន្ត!

**លោក អាកឡូរ វែកគែន៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកសួរបញ្ជាក់សំណួរចុងក្រោយជាថ្មីម្ដងទៀត ពីព្រោះទំនងភ្លេចហើយ សំណួរអំមិញហ្នឹងគឺភ្លេចហើយ ទាំងយើងក៏ភ្លេចដែរ ថាតើលោកសួរគាត់សំណួរអីទេអំមិញនេះ-- អម្បាញ់មិញនេះ។ អ៊ីចឹងតាំងសំណួរនេះជាថ្មី ដើម្បីឲ្យគាត់ស្ដាប់បាន ហើយគាត់អាចឆ្លើយតបបាន។ ហើយសូមឲ្យមេធាវីបោះបង់នូវការព្យាយាម ក្នុងការតាំងសំណួរច្រំដែល។

[១០:៥៨:១៥]

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោកសាក្សី តើលោកបានជួបអ្នកស៊ើបអង្កេតតុលាការប៉ុន្មានដងដែរ?

**លោក អឿន តាន៖**

**ឆ៖** បាទ ខ្ញុំជួបអ្នកស៊ើបអង្កេតឆ្នាំ២០០៨ តែម្តងហ្នឹងបាទ។

**ស៖** តើលោកមានធ្លាប់បានជួបគាត់នៅឆ្នាំណាផ្សេងទៀតទេ?

**ឆ៖** ដូចអត់ដែលទៀតទេបាទ។ ឃើញតែម្តងហ្នឹងបាទ។

**ស៖** តើលោកចាំទេថា លោកបានជួបអ្នកស៊ើបអង្កេតនៅឆ្នាំ២០០៩ គឺប្រាំមួយខែបន្ទាប់ពីកិច្ចសម្ភាសន៍លើកទីមួយ?

**ឆ៖** បាទ ខ្ញុំអត់ចាំបាទ។ កាលនុ៎ងមានមែន អត់ចាំថ្ងៃខែទេបាទ។

**ស៖** នៅក្នុងពេលប្រជុំ-- នៅក្នុងពេលសម្ភាសនោះ តើលោកមានចុះហត្ថលេខាលើកំណត់ហេតុណាទេ?

**ឆ៖** ក្រោយពីសម្ភាសមក ខ្ញុំបានចុះហត្ថលេខាក្នុងខ្លឹមសារពីការសម្ភាសនុ៎ងឯងបាទ។

**ស៖** តើលោកចាំទេថា កាលពីសម្ភាសលើកទីពីរនេះ គេសម្ភាសលោកអំពីអ្វីខ្លះ?

**ឆ៖** បាទ ឲ្យខ្ញុំចងចាំ អត់ចាំទេបាទ មិនដឹងនិយាយពីអីខ្លះ។ ព្រោះការនិយាយទៅវា ពេលគេសម្ភាសចេះតែនិយាយទៅ តែដល់ថ្ងៃនេះខ្ញុំមិនចងចាំទេបាទ។ ព្រោះការសម្ភាសនោះមានការកត់ត្រាក្នុងការសម្ភាសហើយ តែបើថាឲ្យខ្ញុំនិយាយសាឡើងវិញ ដូចជាមិនចងចាំទេបាទ។

**ស៖** ប៉ុន្តែយើងមិនចាំបាច់និយាយលម្អិតអំពីការសម្ភាសនេះទេ គ្រាន់តែថាជាប្រធានបទទូទៅនៃកិច្ចសម្ភាសន៍ហ្នឹង តើលោកចាំទេ?

[១១:០១:២១]

**ឆ៖** បាទ ដូចបានបញ្ជាក់ជម្រាបខាងដើមហើយថា ពេលគេសម្ភាសមកខ្ញុំចេះតែចាំទៅ ការនឹក និយាយក៏ចាំជាប់អីចឹងទៅ ចេះតែនិយាយទៅ អ្នកកត់ត្រាចេះតែកត់ទៅ។ ពេលនោះខ្ញុំចាំអីចឹងបាទ។

**ស៖** តើលោកអាចផ្តល់ឧទាហរណ៍មួយ អំពីសំណួរណាមួយដែលគេចោទសួរលោកបានទេ នៅពេលដែលអ្នកស៊ើបអង្កេតទៅសម្ភាសលោកលើកទីពីរនោះ?

**ឆ៖** ខ្ញុំមិនអាចជម្រាបបានទេ ព្រោះខ្ញុំភ្លេចទៅហើយ បាទ។

**ស៖** កាលពីម្សិលមិញនៅក្នុងសវនាការនេះ គេបានសួរលោកថា៖ “តើលោកស្គាល់ សាឡុត បាន ដែលមានឈ្មោះបដិវត្តន៍ សួរ ហុង ដែរឬទេ?” តើលោកចាំ គេបានសួរលោកអំពី សួរ ហុង នេះ?

**ឆ៖** បាទ ខ្ញុំឮគេសួរដែរ ប៉ុន្តែខ្ញុំថា ខ្ញុំអត់ស្គាល់បាទ។

[១១:០២:៥៩]

**លោក អាកឡូរ វែកកែន៖**

បាទ នេះហើយជាអ្វីដែលខ្ញុំចង់ពិនិត្យផ្ទៀងផ្ទាត់នោះ។ សូមអរគុណលោកសាក្សី។ ដើម្បីឲ្យមានលក្ខណៈពេញលេញច្បាស់លាស់ ចំពោះការសួរសំណួរលោកនោះ ខ្ញុំចង់ដកស្រង់នូវចំណុចដូចតទៅ គឺនៅនាទីទី០៦ វិនាទីទី១០ នាទីទី០៩-- វិនាទីទី២៩ ០១ម៉ោង២៨នាទី ០១វិនាទី។ ទាំងអស់នេះគឺសុទ្ធតែជាឃ្លានៃខ្សែអាត់ ដែលខ្ញុំបាននិយាយអម្បាញ់មិញនេះ។ ហើយដែលក្នុងខ្សែអាត់នោះ គឺមានយោងសំដៅទៅដល់ការសម្ភាសរបស់លោកជាមួយអ្នកស៊ើបអង្កេត កាលពី-- នៅថ្ងៃទី០៨ តុលា ២០០៨។ ខ្ញុំសូមដកស្រង់ដើម្បីខ្លឹមសារនៃការសួរសំណួររបស់ខ្ញុំមានលក្ខណៈពេញលេញ។

ខ្ញុំសូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ចប់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[១១:០៤:២៤]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ សួស្តីលោក អឿន តាន ខ្ញុំ សុន អរុណ មេធាវីការពារលោក នួន ជា។ ខ្ញុំមានសំណួរបួនដប់ដើម្បីសួរលោកនៅថ្ងៃនេះ។

**សួរដោយលោក សុន អរុណ៖**

**ស៖** លោក តាន ចាប់ពីឆ្នាំ១៩៦៨ ដល់ឆ្នាំ១៩៧០ លោកបានចូលជាមួយនឹងបដិវត្តន៍ ធ្វើមានមុខងារជានីរសារ។ លោកខ្ញុំសួរពីមុខងាររបស់លោក នីរសារហ្នឹង តើកិច្ចការហ្នឹងលោកយល់ថា កិច្ចការងារហ្នឹងពិបាក ឬក៏ស្រួល ឬក៏មានគ្រោះថ្នាក់អ្វី អាចផ្តល់មកដល់ខ្លួនលោកទេ?

**លោក អឿន តាន៖**

**ឆ៖** បាទ ខ្ញុំតាំងខ្លួនខ្ញុំកាលរត់នីរសារ គឺអត់មានផលអីលំបាកទេ ពេលខ្លះមានសំបុត្រទៅ

ខ្ញុំរត់នីរសារអ៊ីចឹងទៅ ខ្លះៗអត់ទៅក៏នៅហ្នឹងកន្លែង ពិសេសគឺចាប់ពីឆ្នាំ១៩៧០ បាទ។

**ស៖** អរគុណ។ ចំពោះរូបលោក លោកឆ្លើយថា នីរសារមិនមានការអីពិបាកទេ។ លោករត់នីរសារផ្លូវឆ្ងាយ លោកបានជម្រាបតុលាការថា ពីអណ្តូងមាសរហូតដល់វ៉ឺនសៃ នេះផ្លូវឆ្ងាយ។ តាមផ្លូវអ្នក! ចុះបើសិនជាលោកថាមិនពិបាកទេ លោកមានអារម្មណ៍មួយថា បើសិនជាសត្រូវ ឬខ្មាំងខាងកម្ពុជាប្រជាធិបតេយ្យហ្នឹងបានចាប់លោក ដោយដឹងថា លោកហ្នឹងជានីរសារ។ តើលោកមានអារម្មណ៍អ៊ីចឹងទេ?

**ឆ៖** បាទ ខ្ញុំរត់នីរសារពីរតនគិរីទៅវ៉ឺនសៃ ប៉ុន្តែខ្ញុំអត់មានអារម្មណ៍ទេ អត់មានការខ្លាចទេ ព្រោះផ្លូវព្រៃ ការដើរពីភូមិមួយទៅភូមិមួយហូរហែតាមផ្លូវ ដូច្នោះអត់មានខ្លាចទេបាទ។

[១១:០៦:៥១]

**ស៖** មុនពេលលោកបានធ្វើជានីរសារ គេមាន ថ្នាក់លើគេមានយក លោកបានទៅអប់រំ ឬក៏សិក្សា ឲ្យសិក្សាពីរឿងមុខងាររបស់នីរសារទេ?

**ឆ៖** បាទ ពេលនោះ គឺមាន ដូចបានបញ្ជាក់ពីមុនហើយថាមាន ផៃ ជាប្រធាន។ ដូច្នេះគេហៅប្រជុំណែនាំពីការរត់សំបុត្រ ពីរតនគិរីទៅវ៉ឺនសៃ, ពីរតនគិរី ទៅខាងមណ្ឌលគិរី។ ដូច្នេះ បានបញ្ជាក់ខាងដើមថា ខ្ញុំវាគ្មានអីលំបាក ទៅបីព្រៃ ឬមួយក៏នេះទេ ព្រោះមានភូមិមានអីតាមផ្លូវហូរហែមក។

**ស៖** អរគុណ។ លោកមានដែលឮអំពីនីរសារផ្សេងៗដែលគេធ្វើកន្លែងផ្សេងៗហ្នឹង មានគ្រោះថ្នាក់ ឬក៏មានការភិតភ័យអ្វីខ្លះពីអ្នកដទៃផ្សេងទៀតទេ ដែលគេធ្វើនីរសារដូចគ្នានោះ?

**ឆ៖** បាទ អត់ដែលៗឮទេបាទ។

**ស៖** បើសិនជា អ៎! ខ្ញុំដូរសំណួរខ្ញុំ មិននិយាយបើសិនជាទេ។ លោករត់នីរសារពីអណ្តូងមាសរតនគិរីទៅវ៉ឺនសៃ ផ្លូវហ្នឹងឆ្ងាយ។ លោកអំមិញឆ្លើយថាមិនដែលជួបប្រទះឧបសគ្គ ឬក៏គ្រោះថ្នាក់អ្វីទេ អារម្មណ៍លោកល្អ លោកមានដែលនឹកស្មានថា បើសិនគេ ខាងខ្មាំងគេចាប់លោក លោកដោះស្រាយយ៉ាងម៉េច?

[១១:០៩:០៩]

**ប្រធានអង្គជំនុំះ**

សាក្សីមិនបាច់ឆ្លើយតបទេ! សំណួរបែបឧបមានវិធី អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យភាគីសួរសាក្សីទេ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សុន អរុណ៖**

**ស៖** សួរសំណួរមួយទៀត។ នៅពេលរំដោះបានភ្នំពេញ ពេលនោះលោកមិនទាន់ទៅភ្នំពេញទេ ប្រហែលជា១០ ទៅ១៥ថ្ងៃក្រោយ ដែលរំដោះបានហើយ ដែល ប៉ុល ពត ទៅមុន ពេលនុ៎ងបានលោកទៅតាមក្រោយ ដោយនៅរៀបចំខោអាវ ប្រដាប់ប្រដា ប៉ុល ពត។ ពេលដែលលោកនៅត្រពាំងទឹមហ្នឹង ដែលមិនទាន់បានទៅភ្នំពេញ លោកឃើញទេសភាព ទិដ្ឋភាពទូទៅកន្លែងលោកនៅ ហើយជុំវិញ លោកនៅហ្នឹង មានទិដ្ឋភាពយ៉ាងម៉េច ពេលរំដោះភ្នំពេញបានហើយ ទាំងប្រជាពលរដ្ឋស៊ីវិលធម្មតា ទាំងយោធា?

**លោក អឿន តាន៖**

**ឆ៖** ខ្ញុំឆ្លើយបញ្ហានេះ គឺថាពេលនោះ គឺអត់មានអីទេ គឺថាអត់មានអារម្មណ៍អីទេ ទាំងប្រជាជន ទាំងអង្គភាពខ្ញុំ គឺអត់អីថាជ្រួលច្របល់ ឬមួយក៏យ៉ាងម៉េចៗទេ គឺថាគឺសប្បាយ។ សប្បាយបានន័យថា ព្រោះការរំដោះ ហើយមានការសប្បាយអ៊ីចឹង។ តែមានអារម្មណ៍អីហៅថាស្មុគស្មាញ និងមានអារម្មណ៍អីឲ្យវានេះទេបាទ។

**ស៖** អរគុណ។ ១០ទៅ១៥ថ្ងៃក្រោយលោកបានទៅភ្នំពេញ។ ពេលដែលលោកចេញពីភ្នំពេញ ទៅតាមផ្លូវ អ៎! ចេញពីត្រពាំងទឹមទៅតាមផ្លូវរហូតដល់ភ្នំពេញ លោកមានឃើញទិដ្ឋភាពយ៉ាងម៉េចអំពីប្រជាពលរដ្ឋ អំពីសកម្មភាពចរាចរណ៍ ទាំងអស់ ទិដ្ឋភាពទូទៅហ្នឹងលោកឃើញយ៉ាងម៉េច?

[១១:១១:៣៩]

**ឆ៖** បាទ ខ្ញុំចេញពីត្រពាំងទឹមមកៗភ្នំពេញ គឺថាតាមផ្លូវ គឺថាសភាពប្រជាជនតាមផ្លូវគឺអត់មានអីទេ គឺមានការរស់នៅធម្មតា បាទ។

**ស៖** សូមអរគុណ។ លោកថារស់នៅធម្មតា ចុះប្រជាពលរដ្ឋ លោកអាចដឹងថាពេលហ្នឹងរំដោះភ្នំពេញបានទេ? មានបានឮអ្នកណានិយាយទេ?

**ឆ៖** បាទ គឺឮគេនិយាយហូរហែមក ពីព្រោះកន្លែងខ្ញុំនៅត្រពាំងទឹម វាឆ្ងាយពីភ្នំពេញ។ ដូច្នេះដល់មានរំដោះភ្នំពេញទៅ ឮការនិយាយតៗទៅថា ឈ្នះភ្នំពេញ រំដោះភ្នំពេញហើយ គឺតាមរយៈមាត់មួយទៅមួយ ប្រាប់ផ្លូវហូរហែមកបាទ។

**ស៖** អរគុណ។ ចុះចំពោះចរាចរណ៍តាមផ្លូវ លោកមានឃើញមានជនភៀសខ្លួន ឬក៏អ្នករត់ចុះឡើង ភិតភ័យតាមផ្លូវទេ?

**ឆ៖** ពេលខ្ញុំមកពីកំពង់ចាម មកភូមិត្រពាំងទឹមមក មកដល់ហៅថាព្រែកក្ដាម បានឃើញប្រជាជនចេញពីភ្នំពេញ។ ហើយពេលនោះ ក៏ឃើញអ្នកមានកូន មានចៅ រញ៉េចរញ៉ៃចតាមដងផ្លូវ តាមព្រែកក្ដាមហ្នឹង កាលហ្នឹង។ គេនៅហូរហែតាមផ្លូវព្រែកក្ដាមហ្នឹង។ ហ្នឹងខ្ញុំមកជួបនៅព្រែកក្ដាមហ្នឹងទេ មកចេញពីកំពង់ចាមមកបាទ។

[១១:១៣:៣៨]

**ស៖** អរគុណ។ លុះដល់លោកមកដល់ភ្នំពេញ លោកឃើញទិដ្ឋភាពនៅភ្នំពេញហ្នឹងយ៉ាងម៉េចខ្លះ?

**ឆ៖** ខ្ញុំបានឃើញទិដ្ឋភាពនៅភ្នំពេញគឺស្ងាត់ជ្រងំ អត់មានមនុស្សទេ គឺស្ងាត់តែម្ដង ព្រោះប្រជាជនចេញអស់ហើយ។ ដូចបានឃើញតាមផ្លូវព្រែកក្ដាមអ៊ីចឹង ដូចឃើញកកកុញនៅព្រែកក្ដាម ហើយចូលដល់ភ្នំពេញ ដូចស្ងាត់ អត់មានមនុស្ស បាទ។

**ស៖** នៅភ្នំពេញទាំងជន ប្រជាជនស៊ីវិល ព្រមទាំងយោធា គឺមិនមានឃើញទេ អ៊ីចឹង?

**ឆ៖** បាទ គឺអ៊ីចឹងមែនបាទ។

**ស៖** អរគុណ។ ពេលដែលលោកមកដល់ភ្នំពេញមិនបានឃើញទិដ្ឋភាពអីអ៊ូអរទេ ឃើញស្ងាត់ជ្រងំ។ លោកឆ្ងល់ទេពេលពេលនុ៎ង?

[១១:១៤:៥០]

**ឆ៖** បាទ ពេលនោះ គឺខ្លួនខ្ញុំផ្ទាល់ គឺឆ្ងល់ ព្រោះន៎ែ ស្ងាត់អ៊ីចឹងទៅ ដូចប្រជាជនមិនដឹងទៅខាងណា។ ដូចបានជម្រាបខាងដើមថា ខ្ញុំឃើញតែម្ដុំព្រែកក្ដាមទេ ហើយច្រកផ្សេងៗដែលប្រជាជនចេញ ខ្ញុំមិនដែលឃើញទេ។ ឃើញតែច្រកព្រែកក្ដាមអ៊ីចឹង មានកកកុញតាមព្រែកក្ដាមទៅបាទ។

**ស៖** ពេលដែលរំដោះភ្នំពេញហើយ លោកនៅខាងក្រោយមិនទាន់បានមកភ្នំពេញ ប្រហែលជា ១០ ទៅ ១៥ថ្ងៃ រួចពីហ្នឹង-- លោក ប៉ុល ពត បានមកមុន។ ពេលដែលៗ លោកមកដល់ភ្នំពេញ ពេលហ្នឹងលោកបានធ្វើការជាមួយនឹង ប៉ង់ បើតាមចម្លើយលោកពីម្សិល លោកឆ្លើយថា អ៊ីចឹងមែនទេ?

[១១:១៦:១២]

**ឆ៖** បាទ គឺមែនហើយបាទ។

**ស៖** ខ្ញុំចង់សួរលោកថា ប៉ង់ ដែលលោកបានធ្វើការជាមួយយូរដែរ យូរឆ្នាំដែរ ប៉ង់ ហ្នឹងទទួលខុសត្រូវយ៉ាងម៉េចនៅក្នុងមន្ទីរ៨៧០ ហ្នឹង?

**ឆ៖** អាហ្នឹងគាត់បានទទួលខុសត្រូវរួម ផ្នែក ប៉ង់ ដឹកនាំរួមក្នុង ៨៧០។

**ស៖** ប៉ង់ ហ្នឹងជាមនុស្សយ៉ាងម៉េច? មានចរិតយ៉ាងម៉េច? កាចសាហាវ ឃោរឃៅ ស្លូតបូតអប់រំ ឬយ៉ាងម៉េចដែរតាមលោកសង្កេតឃើញ?

**ឆ៖** បាទ ពេលនោះក៏តាមខ្ញុំសង្កេតឃើញ ប៉ង់ គឺមនុស្សសុភាពរាបសារ ទន់ភ្លន់ជាមួយយុទ្ធជន ទាំងអស់ អត់មានកាចសាហាវទេបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកនៅធ្វើការជាមួយ ប៉ុល ពត នៅត្រពាំងទឹមទុំង ប៉ង់ នៅជាមួយទេ?

**ឆ៖** បាទនៅជាមួយបាទ។

**ស៖** លោក តាន លោកបានធ្វើការជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់ ជាពិសេសលោកជាកងការពាររបស់លោក ប៉ុល ពត។ លោកបើតាម ចម្លើយរបស់លោកនៅក្នុងឯកសារជាមួយចៅក្រមស៊ើបអង្កេត ឬក៏ចម្លើយពីម្សិលមិញជាមួយនឹងភាគីផ្សេងៗ លោកបាននិយាយថា លោកបានស្គាល់លោក នួន ជា ច្បាស់លាស់អ៊ីចឹងមែនទេ?

[១១:១៨:៣៦]

**ឆ៖** បាទ គឺស្គាល់ច្បាស់លាស់បាទ។

**ស៖** លោកបានស្គាល់ច្បាស់លាស់ លោក នួន ជា។ លោក នួន ជា ហ្នឹងជាមនុស្សមានចរិតយ៉ាងម៉េច? មានចរិតជាមនុស្សស្លូតបូត ជាមនុស្សចេះអប់រំមនុស្ស ជាមនុស្សចេះដឹកនាំមនុស្ស ឬកាចសាហាវ យកគេទៅវៃចោល យកគេទៅកម្ទេច ឬក៏ធ្វើបាប ដាក់គុក ដាក់ច្រវ៉ាក់អ៊ីអ៊ីចឹងទៅ គាត់របៀបម៉េច?

**ឆ៖** បាទ តាមការឃើញ តាមការធ្លាប់រស់នៅជាប្រចាំថ្ងៃពេលនោះ គឺលោក នួន ជា នេះគាត់ជាអ្នកហៅថា ស្លូតបូត អ្នកចេះអប់រំ អ្នកចេះណែនាំ ឲ្យប្រជាពលរដ្ឋល្អ ត្រឹមត្រូវ នេះតាមខ្ញុំសង្កេតឃើញ គឺអ៊ីចឹងបាទ។

**ស៖** សូមអរគុណ។ តាមឯកសារ E3/33 ដែលលោកឆ្លើយជាមួយនឹងចៅក្រមស៊ើបអង្កេតថា លោកប្រជុំ-- ពេលប្រជុំមេឃោធានៅស្តាតអូរឡាំពិកនោះ មិនដែលឃើញ នួន ជា មិនដែលឃើញ

លោក ខៀវ សំផន មិនដែលឃើញលោក អៀង សារី ទេ ដើម្បីចូលរួមប្រជុំនោះមិនៗឃើញអ្នកដឹកនាំទាំងបីនេះទេ តែឃើញលោក សុន សេន។ លោកដឹងទេថាហេតុអ្វីបានជាថ្នាក់ដឹកនាំធំខាងលើមិនចូលរួមនៅពេលប្រជុំយោធានោះ? លោកអាចជម្រាបតុលាការបានទេ?

**ឆ៖** បាទ ខ្ញុំជម្រាបបាន ព្រោះពេលនោះកិច្ចការប្រជុំនៅស្តាតអូវឡាំពិក ហៅថាប្រជុំយោធាមាន ប៉ុល ពត អ្នកដឹកនាំប្រជុំ ក្នុងនោះមាន សុន សេន អ្នកចូលរួម។ ហើយខ្ញុំជម្រាបជូនបាន តែយ៉ាងម៉េចបានអត់ឃើញលោក ខៀវ សំផន, នួន ជា, អៀង សារី ពីព្រោះផ្នែកនេះ គេថែមផ្នែកផ្សេង ព្រោះការដឹកនាំ គេហៅដឹកនាំប្រជុំខាងយោធា គឺ សុន សេន ជាមេ ដល់អ៊ីចឹង សុន សេន អ្នកចូលរួមជាមួយ ប៉ុល ពត បាទ។ លោក ខៀវ សំផន, អៀង សារី, នួន ជា អត់ដែលឃើញចូលរួមទេបាទ។

[១១:២១:២៧]

**ស៖** អរគុណ។ លោកថាពេលប្រជុំនោះ ប្រជុំយោធាមានតែមេៗយោធាព្រមទាំង ប៉ុល ពត ហើយនិង សុន សេន។ លោកស្គាល់លោក សុន សេន ច្បាស់លាស់ទេ?

**ឆ៖** បាទ ខ្ញុំឮគេថា លោក សុន សេន ចូលរួមបាទ។ គ្រាន់តែឮៗ គេថាអ៊ីចឹងបាទ។ អត់ដែលឃើញមុខទេបាទ។

**ស៖** លោកដឹងមុខងាររបស់លោក សុន សេន ធ្វើអីៗទេ?

**ឆ៖** ខ្ញុំអត់ដឹងទេបាទ។

**ស៖** លោកៗ នួន ជា គាត់ជាប្រធានរដ្ឋសភា ជាប្រធានរដ្ឋសភាប្រជាជន នៃបក្សកុម្មុយនីស្តកម្ពុជា ហើយគាត់ជាអនុលេខាបក្ស លោក ខៀវ សំផន ជា-- ក្រោយពីសម្តេចនរោត្តម សីហនុ លោកលាលែងគឺលោ ខៀវ សំផន ជាប្រមុខរដ្ឋ ហើយអៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុករដ្ឋមន្ត្រីក្រសួងការបរទេស។ លោកមុខងារធំៗ្លឹងៗ ប៉ុណ្ណឹង ពេលប្រជុំយោធា ហេតុអ្វីបានជាមានដឹងថា ហេតុអីបានជាលោកទាំងបីទាំងបួនហ្នឹងមិនបានចូល?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយបញ្ហានេះខ្លួនខ្ញុំផ្ទាល់ ក៏មិនដឹងជាមូលហេតុយ៉ាងម៉េចទេ មិនបានឃើញលោក ខៀវ សំផន, អៀង សារី, នួន ជា ប្រជុំ។ ហើយជាមូលហេតុអីៗ ខ្ញុំអត់ដឹងទេបាទ ព្រោះអត់ឃើញៗចូលប្រជុំ។

[១១:២៣:២៧]

**ស៖** សូមអរគុណ។ ខ្ញុំសូមដូរសំណួរទៅសំណួរមួយទៀត។ លោកបានឆ្លើយជម្រាបព្រះរាជ

អាជ្ញាថា លោកដែលធ្លាប់ឃើញទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដីយុវជនយុវនារី។ ឥឡូវខ្ញុំសូមបញ្ជាក់ម្ដងទៀត លោកប្រាកដជាបានឃើញមែនទេ?

**ឆ៖** បាទ ពេលនោះខ្ញុំឃើញមែន ឃើញទង់បដិវត្ត ឃើញទស្សនាវដ្ដី គេចែកជូនតាមកន្លែងផ្សេងៗ ដែលខ្ញុំឃើញមែនពិតបាទ។

**ស៖** អរគុណ។ តាមការដែលលោកបានឃើញ លោកអាចជម្រាបតុលាការថា ភិនភាគនៃទង់បដិវត្តនោះរបៀបណា? ជាសៀវភៅ ឬក៏ជាអ្វីៗ? ហើយសៀវភៅនោះមានរូបរាងយ៉ាងម៉េច មានព័ណយ៉ាងម៉េចនៅខាងក្របៗពីខាងក្រៅ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបជូនបញ្ហានេះ ថាទស្សនាវដ្ដី គេដាក់ក្នុងក្របវា គឺមាននារីទូលកណ្ដាប់ស្រូវ ឯទង់បដិវត្តហ្នឹង គឺគេមានដាក់ៗ កណ្ដៀវ ហើយនិងញញួរ បាទ។

[១១:២៥:២០]

**ស៖** អស់ហើយ ហើយនៅមានទៀតទេ? លោកឃើញយ៉ាងម៉េចទៀត?

**ឆ៖** អស់ហើយ បាទ។

**ស៖** អរគុណ។ លោកដែលបានបើកមើលទង់បដិវត្តហ្នឹងទេ?

**ឆ៖** បានបើកមើល ប៉ុន្ដែមិនចេះមើលអក្សរ ពេលនោះអត់ចេះ អត់ចេះអានទេ គ្រាន់តែមើលមើលរូបភាពៗ ឧទាហរណ៍ នារីទូលកណ្ដាប់ស្រូវ មើលរូបភាពទង់ មានកណ្ដៀវ មានញញួរ អ៊ីចឹងទៅតែសរសេរជាអក្សរដែរ ប៉ុន្ដែមើលអត់ដាច់ អត់ចេះមើលបាទ។

**ស៖** សូមអរគុណ។ លោកបានបើកមើលសៀវភៅ ប៉ុន្ដែលោកអានអត់ដាច់។ លោកឃើញអក្សរនោះ ជាអក្សរសរសេរដៃ ឬក៏បោះពុម្ពជាវ៉ៃដាក់ទីឡូ ឬក៏អីអ៊ីចឹងទៅ វាខុសគ្នា។ អាហ្នឹង អាចៗលោកអាចប្រហែលជាយល់។

**ឆ៖** បាទ គឺគេវ៉ៃជាពុម្ពៗ។ នោះ គឺពេលខ្លះ គេថតពណ៌ ជារូបថតពណ៌ ហើយផ្ដិតជាប់នឹងក្របវា បាទ។

**ស៖** អរគុណណាស់។ លោក តាន ធ្លាប់ឃើញទស្សនាវដ្ដីទង់បដិវត្តនេះច្រើនដងទេ ឬក៏ធ្លាប់ឃើញតែម្ដង ឬពីរដង?

**ឆ៖** ដូច្នេះចេញពី-- ចេញទង់បដិវត្តឆ្នាំ៧៥។ ៧៥,៧៦,៧៧ ជាហូរហែមក ហើយឃើញជាញឹកញាប់អ៊ីចឹងបាទ។

**ស៖** លោកជម្រាបតុលាការថា លោកបានឃើញទង់បដិវត្ត លោកបានមើល លោកបានជម្រាបតុលាការថា មានភិនភាគអ៊ីចេះៗ លោកយល់ពីរឿងទង់បដិវត្តគេនិយាយអំពីអីទេ? ឬក៏លោកដែលឮគេប្រាប់ថា ទង់បដិវត្ត គេនិយាយអំពីអីទេ?

**ផ៖** បាទ គឺអត់ដែលដឹងទេ បាទ។

**ស៖** ខ្ញុំត្រឡប់មកសួរ ត្រឡប់ក្រោយបន្តិចពីរឿងប៉ង់។ ពីម្សិលមិញ លោក តាន បានឆ្លើយជម្រាបទៅខាងព្រះរាជអាជ្ញា ពេលដែលដឹងថា បាត់ប៉ង់ លោកអត់ដឹងថា បាត់របៀបណាទេ។ ស្លាប់ ឬក៏គេបញ្ជូនទៅណា ឬក៏ចាប់ ឬអី អត់ដឹងទេ។ ប៉ុន្តែលោកៗថាភ័យខ្លាចផង លោកមិនភ័យផង ពីម្សិលមិញលោកឆ្លើយអ៊ីចឹង។ ប្រាកដមែនទែនហ្នឹង លោកភ័យខ្លាច ឬក៏លោកមិនខ្លាចទេ? មិនភ័យទេ?

[១១:២៩:១៣]

**ផ៖** ខ្ញុំសូមមានមតិអំពីបញ្ហាការបាត់ ប៉ង់ មួយរយៈ។ តែខ្លួនផ្ទាល់គឺថាដូចបានជម្រាបពីម្សិលមិញអ៊ីចឹង គឺបាត់អ៊ីចឹងទៅ ដែលមួយថ្ងៃពីរថ្ងៃបាត់ បីបួនថ្ងៃបាត់។ ខ្លួនបានជម្រាបជូនហើយថា ចេះតែឆ្ងល់ ប៉ង់ ទៅណាអ៊ីចេះ ធ្លាប់រាល់ដងមកពីណាពីណី ធ្លាប់ចូលផ្ទះ មកពីណាពីណីចូលផ្ទះ រួចហើយខ្លួនឆ្ងល់ ចេះតែសាកសួរគ្នា អ្នែ ប៉ង់ មិនដឹងទៅណា? ខ្លះគេថាអត់ដឹងដែរ។ រួចហើយក៏ការភ័យខ្លាចខ្លួនផ្ទាល់ចេះតែមានអារម្មណ៍ ដោយមានមតិណែនាំពី ប៉ុល ពត ថាឥឡូវ ប៉ង់ មិនដឹងទៅណាទេ។ ប៉ុល ពត ថាអ៊ីចឹង។ ឥឡូវពួកអស់ឯងខំធ្វើការងារការពារទៅ កុំភ័យ កុំខ្លាច បាទ។

**ស៖** ខ្ញុំបញ្ជាក់បន្ថែមថា លោកភ័យខ្លាចហ្នឹង ក្នុងអារម្មណ៍លោកយ៉ាងម៉េចបានជាលោកភ័យខ្លាច? លោកដឹងថាប៉ង់ហ្នឹង គេយក-- ប្រាកដមែនទែនថា-- ដឹងប្រាកដមែនទែនថា លោក ប៉ង់ ហ្នឹងគេធ្វើបាប ឬក៏គេសម្លាប់ ឬក៏គេចាប់ ឬក៏ ប៉ង់ ហ្នឹងស្លាប់ដោយខ្លួនឯង ឬយ៉ាងម៉េច?

[១១:៣០:៥៥]

**ផ៖** បាទ ការភ័យខ្លាចហ្នឹងគឺថា ខ្ញុំមិនទាំងដឹងថា ប៉ង់ គេចាប់ឬគេចងអីទេ។ ហើយអត់ដឹងច្បាស់ទេបញ្ហាហ្នឹង ព្រោះខ្លួនគ្រាន់តែយល់ថា បាត់មួយថ្ងៃពីរថ្ងៃអីអ៊ីចឹង ហើយក្នុងខ្លួនចេះតែមានអារម្មណ៍ អាណិត នឹកៗ ព្រោះការធ្លាប់រស់នៅជាមួយគ្នា។ ដល់អ៊ីចឹង គឺមានអារម្មណ៍អ៊ីចឹង។ ហើយការភ័យ ការខ្លាច ដូចបញ្ជាក់ខាងដើមថា យូរៗទៅសាបរលាបទៅ គឺថាលែងគិតលែងគួរហើយ។ ដោយសារទទួលការណែនាំពីតា ប៉ុល ពត គឺថាគាត់ថាឥឡូវមិនបាច់នេះទេ ពួកឯងខំការពារ ខំមើល

កន្លែង ជុំវិញកន្លែង ខំការបង្កបង្កើនផលទៅ ដើម្បីដោះស្រាយជីវភាពក្នុងការហូបចុក។ នេះខ្ញុំសូមថែម ប៉ុណ្ណឹងបាទ។

[១១:៣១:៤៦]

**ស៖** អរគុណ។ ពីម្សិលមិញលោកចៅក្រម ហ្សង់ម៉ាក បានសួរលោកថា ទូរសារទាំងប៉ុន្មាន ដែលយកទៅ-- ដែល ប៉ុល ពត បានឲ្យយកទៅឲ្យលោក នួន ជា តើយក-- លោក តាន យកទៅខ្លួនឯង យកទៅដល់លោក នួន ជា ឬក៏ហុចឲ្យទៅអ្នកណាមុនអ្នកផ្សេង ដើម្បីបញ្ជូនឲ្យលោក នួន ជា?

**ឆ៖** បាទ ពេលនោះគឺថា សារទូរលេខពី ប៉ុល ពត មកគឺយកឲ្យនួន ជា គឺខ្ញុំឲ្យកូនចៅខ្ញុំជូនទៅ ទៅ នួន ជា បាទ។

**ស៖** សូមនិយាយសាថ្មី ឲ្យកូនចៅជូនទៅ នួន ជា ឬក៏ជូនលោកទៅ នួន ជា ឬក៏ថាបញ្ជូន សារហ្នឹង លោកឲ្យកូនចៅយកទៅឲ្យលោក នួន ជា អីចឹង? ឬក៏លោកឲ្យគេជូនលោកទៅជាមួយគ្នា?

**ឆ៖** បាទ អត់ទេ។ ខ្ញុំថាកូនក្រុមខ្ញុំ ៗគេជូនទៅកន្លែង នួន ជា បាទ។

**ស៖** លោកដឹងទេថា សារដែលយកមកឲ្យ-- ពេលដែលគេផ្ញើមកជូនលោក ប៉ុល ពត ដឹងថា សារហ្នឹងមកពីណាទេ?

**ឆ៖** បាទ អត់ដែលដឹងទេបាទ។

**ស៖** ហើយអ្នកណាយកមកឲ្យលោក តាន ដើម្បីយកទៅជូនលោក ប៉ុល ពត?

[១១:៣៣:៥៦]

**ឆ៖** ដូចបានជម្រាបពីម្សិលហើយថា ពី ក-៧។ ពី ក-៧ ជូនមកខ្ញុំ។ ខ្ញុំក៏ទទួលពី ក-៧ យក មកឲ្យ ប៉ុល ពត បាទ។

**ស៖** អរគុណ។

**លោក សុន អរុណ៖**

ខ្ញុំដូចមិនមានសំណួរអីបន្តទៅទៀតទេ សូមអរគុណសាក្សី ហើយនិងសូមអរគុណលោកប្រធាន ផង។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បី មានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ម៉ែខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន លោកស្រី ចៅក្រម និងអស់លោកទាំងអស់ ដែលបានចូលរួមនៅក្នុងសវនាការនេះ។ អរុណសួស្តីលោកសាក្សី។ ខ្ញុំជាមួយនឹងលោក អាង ឧត្តម គឺជាមេធាវីការពារក្តីតំណាងឲ្យលោក អៀង សារី ហើយខ្ញុំមានសំណួរតែពីរបីប៉ុណ្ណោះ ដែលគោលដៅសំខាន់នៃសំណួរនោះគឺដើម្បីបញ្ជាក់លម្អិត។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** នៅថ្ងៃនេះលោកបាននិយាយថា ចម្លើយរបស់លោកទាំងអស់ដែលត្រូវបានកត់ត្រានោះ--ត្រូវបានកត់ត្រាទុក។ តើលោកអាចប្រាប់បានដែរឬទេ ថាតើលោកមានឱកាសដើម្បីស្តាប់ទៅលើការថតសំឡេងនៃចម្លើយទាំងអស់របស់លោកនោះ តើបានដែរឬទេ? តើលោកដែលបានស្តាប់នូវការថតសំឡេងនៃការឆ្លើយតបរបស់លោកទាំងអស់នោះដែរឬទេ?

**លោក អឿន តាន៖**

**ឆ៖** បាទ បញ្ហានេះគឺខ្ញុំភ្លាប់មិនបានទេបាទ។ សូមបញ្ជាក់ម្តងទៀត។

**ស៖** ថ្ងៃនេះលោកបានប្រាប់មកយើងថា នៅពេលដែលលោកផ្តល់ចម្លើយទៅអ្នកស៊ើបអង្កេតគឺការផ្តល់ចម្លើយហ្នឹងត្រូវបានថតជាខ្សែអាត់។ ថាតើនៅថ្ងៃហ្នឹង ឬក៏ពេលដែលលោកមកដល់ហ្នឹងលោកមានឱកាសបានស្តាប់នូវខ្សែអាត់នុំងសាជាថ្មីទេ?

[១១:៣៥:៥៩]

**ឆ៖** បាទ ខ្ញុំអត់ដែលស្តាប់ទេបាទ។

**ស៖** មុនពេលដែលលោកមកផ្តល់នូវសក្ខីកម្មនៅទីនេះ ថាតើមានបុគ្គលណាម្នាក់នៅតុលាការនេះបានអានឲ្យលោកស្តាប់នូវចម្លើយដែលលោកបានផ្តល់ហ្នឹង ថាតើគេមានអាចឲ្យលោកស្តាប់ដែរឬទេដើម្បីឲ្យលោកនឹងឃើញឡើងវិញនោះ?

**ឆ៖** បាទ គឺមាន មានគេអានជូនខ្ញុំបាទ។

**ស៖** នៅក្នុងចម្លើយទីមួយ ដែលលោកផ្តល់ដែលមានលេខ E3/33 គឺវាបានបញ្ជាក់ថា សំណួរចាប់ផ្តើមនៅម៉ោងប្រាំបួន សាមសិបប្រាំ ហើយបញ្ចប់នៅប្រហែលម៉ោងបី សាមសិប រសៀល។ ថាតើនេះជាពេលវេលាដែលត្រឹមត្រូវដែរឬទេ?

[១១:៣៧:០២]

**ឆ៖** បាទ គឺត្រឹមត្រូវ បាទ។

**ស៖** តើលោកចាំដែរឬទេ ថាតើតាមការចាំផ្ទាល់ខ្លួនរបស់លោកហ្នឹង ការសម្ភាសមុនពេលដែលគេថតចម្លើយហ្នឹង តើមានការសម្ភាសដែរឬទេ?

**ឆ៖** បាទ ពេលហ្នឹង គឺមានបាទ។

**ស៖** ដូច្នេះ ខ្ញុំអាចនិយាយបានថា ការសម្ភាសហ្នឹងធ្វើឡើងដោយអ្នកស៊ើបអង្កេតតែមួយ ដែលចោទសួរលោកនៅថ្ងៃបន្ទាប់ បានន័យថាមុនគេថតសំឡេងជាខ្សែអាត់ហ្នឹង គឺមានគេសួរមួយថ្ងៃមុនហ្នឹងហើយ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គឺត្រឹមត្រូវហើយបាទ។

[១១:៣៨:០២]

**ស៖** នេះគឺជាចំណុចដែលខ្ញុំចង់ឲ្យមានការបញ្ជាក់ ថាតើលោកអាចពន្យល់បានដែរឬទេ ថាតើកិច្ចសម្ភាសន៍នោះ គឺកិច្ចសម្ភាសន៍ដែលលោកធ្វើជាមួយនឹងអ្នកស៊ើបអង្កេត គឺនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ ហ្នឹង តើវាមានរយៈពេលប្រហែលប៉ុន្មានដែរ?

**ឆ៖** កាលនុ៎ងខ្ញុំចាំ ដូចជាមួយថ្ងៃកាលនុ៎ងបាទ។

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ ថាយើងយល់នូវសក្ខីកម្មរបស់លោក។ នៅថ្ងៃទី០៨ លោកឆ្លើយចម្លើយពេញមួយថ្ងៃ ហើយនៅថ្ងៃទី០៩ គេសួរសំណួរមកលោក ហើយសំណួរទាំងអស់នោះត្រូវបានគេថតជាខ្សែអាត់។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គឺត្រឹមត្រូវបាទ។

**ស៖** ឥឡូវនេះយើងនិយាយអំពីហេតុការណ៍ ដែលកើតឡើងនៅពេលដែលគេចោទសួរលោកហើយលោកផ្តល់ជាចម្លើយ ប៉ុន្តែនៅពេលដែលគេ-- នោះគឺអត់ថតខ្សែអាត់នោះទេ។ នេះគឺជាការផ្តល់ព័ត៌មានទាក់ទងទៅនឹងព័ត៌មានសង្ខេបនៃការស៊ើបអង្កេត។ តើលោកអាចជម្រាបយើងបានដែរឬទេ ថាតើសំណួរអ្វីខ្លះដែលគេចោទសួរលោកនៅថ្ងៃនោះ ប្រសិនបើលោកចាំ?

[១១:៣៩:៣៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងមិនជំទាស់ទៅលើខ្លឹមសារនោះ ប៉ុន្តែខ្ញុំគិតថាសហភាគារបស់ខ្ញុំបាននិយាយថា កិច្ចសម្ភាសន៍នៅថ្ងៃទី០៨ មិនត្រូវបានថតជាខ្សែអាត់។ ប៉ុន្តែខ្ញុំគិតថា គួរតែបញ្ជាក់ឲ្យច្បាស់ គួរតែនិយាយឲ្យបានច្បាស់នៅថ្ងៃទី០៨ គឺថ្ងៃដែលអត់មានថតជាខ្សែអាត់នោះ។

**លោក ម៉ែខល កាណាវាស៖**

ជាការត្រឹមត្រូវ ខ្ញុំគិតថា បញ្ហានេះប្រហែលជាច្បាស់លាស់ហើយ ព្រោះមេធាវីការពារក្ដី ខៀវ សំផន បានបញ្ជាក់រួចហើយ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** តើលោកដឹងដែរឬទេ ថាតើនៅថ្ងៃទី០៨ គឺថ្ងៃដែលលោកនិយាយថាគេសួរលោកពេញមួយថ្ងៃនុ៎ង ថាតើថ្ងៃទី០៨ នុ៎ង គេមានថតជាខ្សែអាត់ឬទេ?

**លោក អឿន តាន៖**

**ឆ៖** បាទ ពេលនុ៎ងដូចៗអត់មានទេបាទ តាមការពិនិត្យ ពិចារណារបស់ខ្ញុំពេលនេះ គឺអត់ឃើញមាន។

**ស៖** ដូច្នេះ តើលោកចាំថាលោកមានជម្រាបដល់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ដោយគេចោទសួរនូវសំណួរ ហើយខ្ញុំសូមដកស្រង់ពីក្នុងខ្សែអាត់ នៅពេលដែលយើងគឺឯកសារ D107/2R នៅនាទីប្រាំៗ រហូតដល់នាទីទីប្រាំមួយ។ នៅពេលនោះលោកបានជម្រាបដល់សហចៅក្រមស៊ើបអង្កេត ឬក៏ថាអ្នកស៊ើបអង្កេតគឺថាលោកបានបញ្ជាក់ថាលោកបានឆ្លើយចម្លើយនេះរួចហើយ។ ប៉ុន្តែដោយគេប្រាប់វិញថា ឥឡូវនេះគឺគេថតជាសំឡេង។ តើលោកចាំដែរឬទេ អំពីបញ្ហានេះ?

[១១:៤១:៤៩]

**ឆ៖** បាទ ការក្ដាប់តាមដានជាប់ទៅ គឺថាដូចខ្ញុំមិនចាំសោះបញ្ហាហ្នឹង។ ព្រោះពេលនោះ ខ្ញុំការសម្ភាស ខ្ញុំចេះតែនិយាយទៅ ដោយខ្ញុំមិនបានពិនិត្យតាមដានការថតសំឡេង ឬមួយការថតអីទេ ដោយខ្ញុំមិនចាំដែរពេលនោះបាទ។ ខ្ញុំជម្រាបត្រង់ជូនព្រះរាជអាជ្ញា និងលោកប្រធានបាទ។

**ស៖** ឥឡូវនេះយើងបន្ត ប្រសិនបើយើងមានពេល យើងអាចនឹងចាក់ឡើងវិញនូវខ្សែអាត់នោះ។ ហើយខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះអាចស្ដាប់ទៅលើការខ្សែអាត់នោះ។ តើលោកចាំដែរឬទេ ថាតើសំណួរ

អ្វីខ្លះដែលគេបានសួរទៅលោក គឺសួរនៅថ្ងៃ គឺមួយថ្ងៃមុនថ្ងៃដែលគេថតសំឡេងលោកជាខ្សែអាត់នោះ?

**ឆ៖** បញ្ហានេះ ខ្ញុំពិបាកឆ្លើយដែរ ព្រោះខ្ញុំអត់-- មិនចាំសោះ។ ដូចបានជម្រាបជាហូរហែ ថាខ្ញុំមិនចាំ។ គំនិតវាអន់ ដូច្នេះគឺមិនចាំទេ។ ពេលកិច្ចសម្ភាសន៍ក៏ខ្ញុំចេះនិយាយទៅពេលនោះ។ ដូចដល់ពេលនេះ ខ្ញុំមិនចាំទេ ខ្ញុំប្រាប់ត្រង់អ៊ីចឹង។ ដូចបានបញ្ជាក់ជូនលោកប្រធានអ៊ីចឹង។

[១១:៤៣:១៥]

**ស៖** ប្រសិនបើខ្ញុំស្នើសុំឲ្យលោកប្រាប់យើងថាតើមាន-- ថាតើគេមានបង្ហាញឯកសារ ឬក៏គេមានអានឯកសារអីឲ្យលោកស្ដាប់ដែរឬទេ? គឺថាអ្នកស៊ើបអង្កេតហ្នឹង គាត់មានអានឯកសារដើម្បីឲ្យលោកនឹកឃើញ ឬក៏ឲ្យលោកចងចាំអ្វីដែរឬទេនៅពេលនោះ?

**ឆ៖** ពេលនោះ គេន័ខាងស៊ើបអង្កេត គេសម្ភាសជាមួយខ្ញុំហើយ ចប់ហើយ ក៏គេអានជូនឲ្យខ្ញុំស្ដាប់ ពីព្រោះខ្ញុំអានខ្លួនឯង ខ្ញុំអត់ចេះអក្សរ។ ដល់អ៊ីចឹងក៏ខាងអ្នកសង្កេតការណ៍ហ្នឹង គឺថាមកសម្ភាសជាមួយខ្ញុំ ខ្ញុំឲ្យគេអានឲ្យ អានជូនខ្ញុំហ្នឹងណ៎ា អាហ្នឹង។ ខ្ញុំក៏ស្ដាប់បានបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ប៉ុន្តែខ្ញុំចង់និយាយអំពីថ្ងៃដែលគេសម្ភាសលោក គឺថ្ងៃដែលមិនមានថតសំឡេង មិនមានថតខ្សែអាត់។ ថាតើនៅថ្ងៃដែលគេចោទសួរទុំង ថាតើអ្នកស៊ើបអង្កេតនោះគាត់មានអានឯកសារ ឬក៏ខ្លឹមសារអត្ថបទអ្វីខ្លះទេ ដើម្បីឲ្យលោកនឹកឃើញ ឬក៏ឲ្យលោកចងចាំនោះ? ប្រសិនបើលោកចាំ ថាតើវាមានការអានឲ្យស្ដាប់បែបនេះដែរឬទេ?

[១១:៤៤:៤៣]

**ឆ៖** បាទ ពេលនោះ ខ្ញុំអត់ចាំបាទ ដូចបានជម្រាបហើយ ខ្ញុំអត់ចាំតែម្ដងបាទ។

**ស៖** ដូច្នេះ ខ្ញុំគិតថាវាអត់មានប្រយោជន៍អីចំពោះខ្ញុំទេ ក្នុងការសួរអំពីប្រធានបទដែលបានពិភាក្សានៅក្នុងថ្ងៃនោះ។ អំពីអ្វីដែលលោកបានចងចាំ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីតាំងសំណួរម្ដងទៀត។ យើងអត់ដឹងថាតើលោកនិយាយចុងក្រោយអំមិញនេះជាការសួរ ឬក៏ជាការកត់សម្គាល់របស់លោកទេ? សាក្សីមិនអាចឆ្លើយបានទេ ប្រសិនបើលោកប្រើពាក្យត្រឹមតែ កម្រិតហ្នឹង ជាភាសាខ្មែរមិនអាចយល់ទេ ថាតើជាសំណួរ ដែលគាត់ឲ្យឆ្លើយ ឬក៏យ៉ាងដូម្ដេច?

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

[១១:៤៥:៥0]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើលោកចាំដែរ ឬទេ ថាតើមានប្រធានបទអ្វីដែលលោកពិភាក្សាជាមួយនឹងអ្នកស៊ើបអង្កេត? គឺនៅថ្ងៃដែលគេសួរលោកដោយមិនមានថតខ្សែអាត់ គឺមួយថ្ងៃមុនពេលគេសួរលោកដោយថតខ្សែអាត់នោះ?

**ឆ៖** បាទ បញ្ហានេះ សូមពិភាក្សាជាមួយមេធាវីសិន ព្រោះខ្ញុំក្តាប់មិនបានសោះបញ្ហានេះ បាទ។

**ប្រធានអង្គជំនុំ៖**

សាក្សី យើងមិនអនុញ្ញាតឲ្យធ្វើការពិភាក្សាជាមួយមេធាវីទេ យើងប្រាប់ហើយ។ លោកពិភាក្សាជាមួយមេធាវីបានចំពោះសំណួរឯណា ដែលសួរឲ្យលោកឆ្លើយដាក់ពិរុទ្ធភាពខ្លួនឯង ទម្លាក់កំហុសខ្លួនឯង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនុ៎ង។ ហើយសំណួរនេះគឺលោកឆ្លើយតាមលទ្ធភាព សមត្ថភាពដែល លោកយល់ដឹង និងចងចាំ។

ឆ្លើយតបនឹងសំណួរ!

**លោក អឿន តាន៖**

**ឆ៖** បាទពេលនោះខ្ញុំបានជម្រាបហើយថា លទ្ធភាព និងសមត្ថភាព ខ្ញុំឆ្លើយមិនចងចាំទេបាទ។ ភ្លេចមុខ ភ្លេចក្រោយ វង្វេង បាទ។

[១១:៤៧:១៨]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** នេះគឺជាសំណួរដែលខ្ញុំចង់សួរបន្ទាប់។ ថ្ងៃនេះលោកបានជម្រាបមកយើងថា លោកមិនយល់អំពីនយោបាយ លោកមានការច្របូកច្របល់ហើយលោកភ្លេចភ្លាំងច្រើន លោកមិនចេះ អក្សរទៀត។ ថាតើលោកភ្លេចហើយមិនចងចាំដែរឬទេ នៅពេលដែលលោកជាមួយអ្នកស៊ើបអង្កេត មកពីការិយាល័យសហស៊ើបអង្កេតនោះ? គឺនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨។ នៅពេលដែលគេសួរលោក ហើយចម្លើយទាំងអស់នោះគឺ មិនត្រូវបានគេថតជាសំឡេង។ តើលោកមានការភ្លេចភ្លាំងដែរឬទេ នៅពេលនោះ?

**ឆ៖** បាទ ដូចបានជម្រាប គឺភ្លេចភ្លាំងតែម្តង។ ភ្លេចភ្លាំងអស់។

[១១:៤៨:១៦]

**ស៖** តើអ្នកស៊ើបអង្កេតគាត់មានជួយលោកក្នុងការរំឭកឡើងវិញ ដោយជម្រាបប្រាប់លោក ដោយផ្តល់ព័ត៌មានដល់លោក ដែលអាចជួយដល់លោកបានសម្រាប់ថ្ងៃបន្ទាប់ដែរឬទេ នៅពេលដែលគេថត អ៎! នៅពេលដែលគេសួរសំណួរលោក ហើយគេថតសំឡេងរបស់លោក។ តើបែបនេះមែនទេ?

**ឆ៖** អានេះ ខ្ញុំពិបាកឆ្លើយណាស់បាទ។

**ស៖** ខ្ញុំសូមអរគុណច្រើនដល់លោក ហើយក្នុងនាមជា-- ក្នុងនាមក្រុមរបស់ខ្ញុំ ក្នុងនាមលោក អៀង សារី ខ្ញុំ សូមថ្លែងអំណរគុណចំពោះលោកសាក្សីដែលបានអញ្ជើញមកចូលរួមក្នុងនេះ ហើយខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកប្រធានខ្ញុំមិនមានសំណួរអ្វីទៀតទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោក អឿន តាន កិច្ចដំណើរការសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មរបស់លោកឃើញថាដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះសូមអរគុណចំពោះសាក្សី ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ក្នុងរយៈកាលមួយថ្ងៃកន្លះ ដោយភាពអត់ធ្មត់ និងខិតខំប្រឹងប្រែងអស់ពីលទ្ធភាពដែលមាន ហើយរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ ហើយលោកអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោក ឬក៏គោលដៅដែលលោកចង់ ធ្វើដំណើរត្រឡប់ទៅវិញបានហើយ ហើយសូមលោកធ្វើដំណើរទៅ ត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១១:៥០:00]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងមន្ត្រីគាំពារសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ ឬក៏ទៅគោលដៅដែលគាត់ចង់ទៅវិញផង។ ហើយដំណើរការសវនាការស្តាប់សម្រាប់ថ្ងៃនេះ ក្នុងការស្តាប់សាក្សី អឿន តាន ឃើញថាបានចប់មុនពេលវេលាដែលបានគ្រោងទុក។ ហើយដល់ពេលក៏សមល្មមនឹងសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃអង្គារ ទី១៩ ខែមិថុនា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគី និងសាធារណជនផងដែរថា ការធ្វើសវនាការសប្តាហ៍ក្រោយនឹងចាប់ផ្តើម នៅថ្ងៃអង្គារ ទី១៩ ខែមិថុនា ឆ្នាំ២០១២ ដោយធ្វើដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សីចំនួនពីររូប ដែលមានរហស្សនាម TCW-797 ហើយនិង TCW-321។ ក្នុងករណី

ចាប់បាច់សវនាការ អាចបន្តធ្វើនៅព្រឹកថ្ងៃសុក្រ ទី២២ ខែមិថុនា ឆ្នាំ២០១២ ផងដែរ។ ការតាំងសំណួរដេញដោលចំពោះសាក្សីពីររូប នឹងធ្វើឡើងដោយតំណាងសហព្រះរាជអាជ្ញាមុនភាគីដទៃទៀត។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា មានបញ្ហាអីទៅ?

[១១:៥១:៣០]

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមដាក់សំណើដោយសង្ខេប ដោយសារតែយើងបាននិយាយអំពីនៃការថតសំឡេង នៅថ្ងៃ០៩ ខែតុលា ២០០៨ ហើយខ្ញុំគិតថា មេធាវីបាននិយាយដូច្នេះ។ ដែលនិយាយអំពីការសម្ភាសនៅថ្ងៃទី០៨ ហើយសាក្សីបានបញ្ជាក់បែបនេះ ហើយបញ្ជាក់ថា មានការកើតឡើងបែបនេះ។ ដូច្នេះ ខ្ញុំគិតថា ជាដំបូងបំផុត គឺយើងត្រូវស្វែងរកនូវប្រតិចារឹកនៃកិច្ចសម្ភាសថ្ងៃទី០៩ ខែតុលា ២០០៨ ហើយបន្ទាប់មកយើងពិចារណា ទៅលើសំណើទៅការិយាល័យសហចៅក្រមស៊ើបអង្កេត អំពីការកត់ត្រានៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ ប្រសិនបើមាន។ ខ្ញុំគិតថា យើងធ្វើដូច្នេះដើម្បីស្វែងរកការពិត ព្រោះថាឥឡូវនេះ គឺមានការសង្ស័យដែលថា មានទាក់ទងទៅនឹងការថតសំឡេងក៏ដូចជាកំណត់ត្រា។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំបានផ្ញើនូវសាររួចទៅហើយ ហើយខ្ញុំមានផ្នែកដែលខ្ញុំអាចចាក់បាន ប៉ុន្តែខ្ញុំចង់-- ដើម្បីកុំឲ្យខាតពេលវេលា។ ដូច្នេះ ខ្ញុំគិតថា នេះគឺជាភស្តុតាង ហើយអ្វីដែលសាក្សីបានឆ្លើយនោះគឺ បានថតរួចទៅហើយ ដូច្នេះ យើងមិនចាំបាច់ត្រូវធ្វើការបញ្ជាក់អ្វីនោះទេ។

[១១:៥២:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន អង្គជំនុំជម្រះមិនចាំបាច់សម្រេចបញ្ហានេះទៀតទេ។ ភាគីពាក់ព័ន្ធអាចដាក់បញ្ហានេះនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន រៀងៗខ្លួនមកអង្គជំនុំជម្រះ ទោះបីសេចក្តីសន្និដ្ឋាននោះពាក់កណ្តាលទី ឬសេចក្តីសន្និដ្ឋានបញ្ចប់ក៏ដោយ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ទាំងបីនាក់ មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃអង្គារ ទី១៩ ខែមិថុនា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែក លោក អៀង សារី ប្រសិនបើគាត់បង្ហាញ

ជំហរច្បាស់លាស់ ក្នុងការលះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការ ដោយមានពាក្យសុំជាលាយលក្ខណ៍អក្សរ ដូចសព្វដងនេះ តាមរយៈមេធាវីការពារក្តីរបស់គាត់ ធ្វើបានមុនពេលអង្គជំនុំជម្រះដំណើរការសវនាការ សូមលោកអនុរក្សមន្ទីរឃុំឃាំងទំនាក់ទំនង ជាមួយនឹងក្រឡាបញ្ជីសវនាការ ដើម្បីទទួលព័ត៌មាន។ ហើយបើមានករណីដូច្នេះកើតឡើង គឺអនុញ្ញាតឲ្យនាំគាត់មកត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ដែលមានឧបករណ៍សោតទស្សន៍ សម្រាប់រូបគាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ អង្គជំនុំជម្រះនឹងពិនិត្យពិចារណា សម្រេចលើពាក្យសុំរបស់គាត់ បានមុនពេលចាប់ផ្តើមសួរដេញដោលសាក្សី។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១១:៥៤ នាទី)*